**BBI0092**

## សម្ភាសជាមួយឈ្មោះ វង់ ខន ភេទ ប្រុស អាយុ ៦០ឆ្នាំ

មុខងារខ្មែរក្រហមៈ ធ្វើទាហាន

មុខងារបច្ចុប្បន្នៈ ធ្វើស្រែ ធ្វើចំការ

មានស្រុកកំណើតនៅៈ ភូមិពងទឹក ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ

សព្វថ្ងៃរស់នៅភូមិភ្នំព្រឹក ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០០:៥០:៤៧

៤១ ទំព័រ

ដានី : បាទ!មនដំបូងខ្ញុំសុំស្គាល់ឈ្មោះពូ ពូឈ្មោះពេញឈ្មោះអីដែរ?

ខន : ខ្ញុំឈ្មោះ វង់ ខន ។

ដានី : វង់ ខន?

ខន : បាទ!

ដានី : បាទ!អាយុប៉ុន្មានហើយពូសព្វថ្ងៃ?

ខន : ខ្ញុំអាយុបើគិតដល់ឥឡូវអាយុ៦០ ។

ដានី : ៦០ឆ្នាំ?

ខន : បាទ!

ដានី : ពូស្រុកកំណើតកើតជានៅណាដែរ?

ខន : នៅត្រាំកក់ នៅភូមិទឹកពង ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ ។

ដានី : ភូមិ?

ខន : ពងទឹក ។

ដានី : ភូមិពងទឹក ។

ខន : ឃុំគូស ។

ដានី : ឃុំគូស?

ខន : បាទ!

ដានី ៖ ស្រុកត្រាំកក់?

ខន ៖ ស្រុកត្រាំកក់ ។

ដានី ៖ ខេត្តតាកែវ?

ខន ៖ ខេត្តតាកែវ ។

ដានី ៖ បាទ!សព្វថ្ងៃពូរស់នៅក្នុងភូមិឃុំអីដែរ?

ខន ៖ ភូមិភ្នំព្រឹក ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

ដានី ៖ ភូមិភ្នំព្រឹក ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង?

ខន ៖ បាទ!ខេត្តបាត់ដំបង ។

ដានី ៖ ពូគ្រួសារពូ ប្រពន្ធពូគាត់ឈ្មោះអីដែរ?

ខន ៖ ឈ្មោះ ព្រំ វឿន ។

ដានី ៖ បាទ!ឈ្មោះ ព្រំ វឿន?

ខន ៖ បាទ!

ដានី ៖ គាត់អាយុប៉ុន្មានដែរ?

ខន ៖ គាត់អាយុ៥៨ ។

ដានី ៖ អាយុ៥៨ឆ្នាំ ស្រុកកំណើតគាត់នៅណាដែរ?

ខន ៖ ខេត្តបន្ទាយមានជ័យ ។

ដានី ៖ ស្រុកកំណើតនៅភូមិអីដែរ?

ខន ៖ នៅភូមិបូសទន្លាប់ ។

ដានី ៖ បូសទន្លាប់ ។ ឃុំអីហ្នឹង?

ខន ៖ អត់ដឹងអត់ដឹងអីទេ ។

ដានី ៖ អត់ដឹងទេ ស្រុកអីហ្នឹង?

ខន ៖ ភូមិបូសទន្លាប់ ឃុំចំណោទ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យហ្នឹង ។

ដានី ៖ ពូមានកូនចៅប៉ុន្មាននាក់ដែរ?

ខន ៖ កូនខ្ញុំ៣នាក់ ប្រុសទាំងពីរនាក់ ស្រី១នាក់ ។

ដានី ៖ ប្រុសពីរ ស្រី១នាក់?

ខន ៖ បាទ!

ដានី :	បាទ!ហើយសព្វថ្ងៃពូប្រកបរបររកស៊ីធ្វើអីដែរ?

ខន :	ធ្វើតែចំការតិចតួចហ្នឹងអូន ។

ដានី :	ធ្វើចំការ ធ្វើចំការអីខ្លះ?

ខន :	ដាំពោត ដាំសណ្ដែកហ្នឹង មានដីតិចតួច ។

ដានី :	ដាំពោត ដាំសណ្ដែក?

ខន :	បាទ!

ដានី :	អត់មានធ្វើស្រូវអីទេ?

ខន :	អត់ទេ!ធ្វើតែខុសពិបាកលក់សងគេ ធ្វើប្រវាសនឹងធម្មជាតិ ប្រវាសនឹងមេឃ ភ្លៀងម៉ោក៏ត្រូវទៅ អត់ភ្លៀងក៏ខុសទៅ ។

ដានី :	អត់ដាំគាឡូងអីទេ ពូថាគាឡូងបានថ្ងៃបានអី?

ខន :	អត់ដាំ អត់ទាន់បានដាំផង ។

ដានី :	អត់ទាន់បានដាំ,

ខន :	បាទ!

ដានី :	ពូមានដីច្រើនដែរ?

ខន :	អត់ទេ!ដីមានប្រហែល២០រ៉ៃហ្នឹង អត់មានដីហ្នឹងគេផង ។

ដានី :	មានដី២០រ៉ៃទេ?

ខន :	បាទ!ប្រហែលជា៣ហិចតា ។

ដានី :	ប្រហែល៣ហិចតា?

ខន :	បាទ!៣ហិចតា កូន៣នាក់ ។

ដានី :	បាទៗ!ចុះពូនៅធ្វើទាហានទៀតឬអត់ទេ?

ខន :	អត់ទេ!ប្រជាជនធម្មតាមានធ្វើទាហានទៀត ។

ដានី :	ប្រជាជនធម្មតា?

ខន :	បាទ!ប្រជាជនធម្មតាយូរហើយ តាំងពីគេផ្ដាច់ខ្លួនហ្នឹងម៉ោអត់រហូត ។

ដានី :	បាទ!ចុះពូឪពុកពូគាត់ឈ្មោះអីដែរ?

ខន :	ឪពុកខ្ញុំឈ្មោះ វង់ ខេង ។

ដានី :	វង់ ខេង?

ខន :	បាទ!

ដានី :	សព្វថ្ងៃគាត់នៅរស់ទេ?

ខន :	នៅរស់ទេ អាយុ៨០ជាងហើយ ។

ដានី :	អាយុ៨០ជាងហើយ អាយុវែង?

ខន :	បាទ!អាយុគាត់៨៥-៨៦ហើយ ។

ដានី :	គាត់នៅណាសព្វថ្ងៃ?

ខន :	គាត់នៅត្រាំកក់ ខេត្តតាកែវ ។

ដានី :	ស្រុកកំណើតរបស់ពូ?

ខន :	បាទ!នៅស្រុកកំណើត ។

ដានី :	ចុះម្ដាយ?

ខន :	ម្ដាយឈ្មោះ នាង ខែម គាត់ស្លាប់ហើយ ។

ដានី :	គាត់ស្លាប់ពីអង្កាល់ទៅ?

ខន :	ស្លាប់១ឆ្នាំហើយ ។

ដានី :	ទើបស្លាប់មួយឆ្នាំទេ?

ខន :	បាទៗ!ទើបស្លាប់១ឆ្នាំទេ ។

ដានី :	ពូមានបងប្អូនប៉ុន្មាននាក់ដែរ?

ខន :	ខ្ញុំមានបងប្អូន៤នាក់ ។

ដានី :	ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ខន :	ប្រុសទាំង៤ ។

ដានី :	ប្រុសទាំង៤?

ខន :	បាន!

ដានី :	ពូកូនទីប៉ុន្មាន?

ខន :	ខ្ញុំកូនទី១ បងគេបង្អស់ កូនទី១ ។

ដានី :	ពូកាលពីក្មេងៗពូធ្លាប់បានរៀនសូត្រអីដល់ណាដែរ?

ខន :	ខ្ញុំរៀនបានថ្នាក់ទី៧ជំនាន់សម្ដេចឪ ។

ដានី :	ពូឈប់រៀនឆ្នាំណាទៅ?

ខន : ឈប់រៀនរដ្ឋប្រហារឆ្នាំ៧០ ។

ដានី : បាទ!

ខន : គោលបំណងថាធ្វើគ្រូបង្រៀនដល់ពេលធ្វើរដ្ឋប្រហារទៅ បញ្ចប់ទៅ ។

ដានី : បាទ!គោលបំណងថារៀនដល់ធ្វើគ្រូដែរ ប៉ុន្តែ?

ខន : បាទ!រៀនធ្វើគ្រូបង្រៀន គោលបំណងចង់បានតាំងពីតូច គ្រូបង្រៀនតែរៀនអត់បាន រដ្ឋប្រហារហ្នឹងក៏ឈប់ទៅ ចប់ ។

ដានី : បាទ!ដល់ពេលឈប់ហើយ ធ្វើអីទៀត?

ខន : ឈប់ហើយ ដល់ឆ្នាំ៧១នោះធ្វើទាហាន ។

ដានី : បាទ!

ខន : ទាហានជំនាន់នោះ ទាហានរណសិរ្សរួបរួមជាតិនោះ ។

ដានី : បាទ!

ខន : ទាហានវ៉ៃលន់ ណុល ។

ដានី : កាលហ្នឹងយ៉ាងម៉េចគេជ្រើសរើសឲ្យចូល ឬក៏ពូស្ម័គ្រចិត្តចូល?

ខន : គេជ្រើសរើសឲ្យចូល ។

ដានី : គេជ្រើសរើសយ៉ាងម៉េចកាលហ្នឹងពូអាច?

ខន : ជ្រើសរើសគេថាយើងធ្វើជាស្នូល យើងចូលជាសម្ព័ន្ធយុវករ ចូលជាបក្សអីគេកាល ហ្នឹង សរសេរជាគំរូអ្នកក្រីក្រ ធ្វើគំរូគេហ្នឹង ។

ដានី : បាទ!

ខន : បាទ!ចូលតស៊ូ ។

ដានី : បាទ!ចូលតស៊ូ?

ខន : បាទ!

ដានី : កាហ្នឹងចូលតាមរយៈណា តាមរយៈភូមិឃុំ ឬតាមរយៈអី?

ខន : តាមរយៈភូមិឃុំកាលហ្នឹង ។

ដានី : តាមរយៈភូមិឃុំ?

ខន : បាទ!

ដានី : ភូមិណាដែរពូចូល?

ខន :	នៅក្នុងភូមិខ្ញុំហ្នឹង ភូមិពងទឹក ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវហ្នឹង ។

ដានី :	បាទ!

ខន :	បាទ!ដំបូងធ្វើឈ្លបភូមិ អស់ពីឈ្លបភូមិ ឈ្លបឃុំ ។

ដានី :	អ្ហូ!

ខន :	ឈ្លបឃុំ ឡើងទ័ពស្រុកឡើងខេត្ត ។

ដានី :	អ្ហូ!

ខន :	ភូមិភាគអញ្ចឹងម៉ង ។

ដានី :	អ្ហូ!ដំបូងយើងធ្វើឈ្លបឃុំ?

ខន :	បាទ!ឈ្លបឃុំ អស់ពីឈ្លបឃុំឡើងស្រុកៗ ។

ដានី :	បាទ!កាលហ្នឹងចូលធ្វើឈ្លបឃុំប្រហែល?

ខន :	ឈ្លបឃុំប្រហែលជា២-៣ខែគេបញ្ជូនទៅស្រុកទៅ ។

ដានី :	អ្ហូ!

ខន :	បាទ!ដល់ទៅទ័ពស្រុកប្រហែលបាន២-៣ខែទៀតទៅទ័ពតំបន់ទៅ ។

ដានី :	អ្ហូ!

ខន :	បាទ!ដល់ទ័ពតំបន់វៃវីកវើនបញ្ជូនទៅទ័ពភូមិភាគទៀតទៅ ។

ដានី :	កាលហ្នឹងទ័ពស្រុក ស្រុកណា?

ខន :	ស្រុកត្រាំកក់ ។

ដានី :	ស្រុកត្រាំកក់?

ខន :	បាទ!

ដានី :	ពេលទ័ពតំបន់ឆ្នាំណាបានទៅចូលស្រុក?

ខន :	ទ័ពតំបន់ ចូលស្រុកត្រាំកក់បាន១ឆ្នាំបានឡើងទ័ពតំបន់ ។

ដានី :	ឆ្នាំណាបានឡើង?

ខន :	ឆ្នាំ៧២ ។

ដានី :	ឆ្នាំ៧២ឡើងទៅតំបន់?

ខន :	តំបន់ ។

ដានី :	នៅតំបន់ណា?

ខន : តំបន់តាកែវហ្នឹង ខេត្តតាកែវ ។

ដានី : គេហៅតំបន់ប៉ុន្មានកាលហ្នឹង?

ខន : គេហៅតំបន់១៣ ។

ដានី : តំបន់១៣?

ខន : បាទ!

ដានី : ឡើងដល់ទ័ពតំបន់?

ខន : បាទ!

ដានី : កាលហ្នឹង កាលយើងចូលធ្វើឈ្លបភូមិ?

ខន : ឈ្លបឃុំ ។

ដានី : ឈ្លបភូមិឬឈ្លបឃុំ?

ខន : ឈ្លបភូមិហើយបានឈ្លបឃុំ ។

ដានី : បាទ!យើងចូលហ្នឹងតាមរយៈប្រធានភូមិ ឬតាមអី?

ខន : តាមរយៈប្រធានភូមិ តាមរយៈអីតាមឃុំ ។

ដានី : តាមរយៈឃុំ ពីណាគេកាលហ្នឹងមានចាំទេ?

ខន : ឈ្មោះ ពូ ឆេនៗនៅអន្លង់វែងសព្វថ្ងៃនេះ ។

ដានី : នៅអន្លង់វែង?

ខន : បាទ!គេមេខ្មែរក្រហមចាស់នៅអន្លង់វែង ។

ដានី : អ៊ូ!បាទ កាលចូលទៅកាលហ្នឹងកាលជំនាន់ពូចូលទៅម្នាក់ឯងឬក៏មាន?

ខន : អេស៎!ចូលគ្នាច្រើនកាលហ្នឹងគេជ្រើសរើស ដំបូងគេធ្វើជាស្នូលដឹកនាំ ជាសម្ព័ន្ធនេះជាសម្ព័ន្ធនោះ ។

ដានី : ប៉ុន្មាននាក់ទៅកាលហ្នឹង?

ខន : អេស៎ចូលបើអ្នកក្រីក្រជាងគេ បានគេរើសយើង បើអ្នកកណ្ដាលគេអត់រើសទេ ។

ដានី : ម៉េចអញ្ចឹងកាលនោះ?

ខន : គេថា អ្នកកណ្ដាលគេថា ជាអនុធន ជាអីគេម៉េចមិនដឹងទេ ជំនាន់ហ្នឹងយើងនៅក្មេងៗ ដែរចាំអត់បានរហូតដល់ឥឡូវហ្នឹង ។

ដានី : បាទៗ!

ខន : ពាក្យថាអនុធន បើយើងក្រីក្រគេហៅតែអាអ្នកក្រីក្រ ។

ដានី : បាទ!

ខន : ដូចថាយើងអ្នកក្រីក្រសម្រាប់ដឹកនាំឲ្យគេ ។

ដានី : បាទៗ!

ខន : បាទ!ចូលទៅបម្រើគេហ្នឹង ។

ដានី : បាទៗ!ពូបានហាត់កងទ័ពកងអី យុត្តិសាស្រ្តអី?

ខន : អេស៎!បានហាត់កងទ័ពយុត្តិសាស្រ្តហាត់ច្រើន ។

ដានី : ហាត់នៅណាកាលហ្នឹង?

ខន : ហាត់នៅស្វាយរមៀលនោះ នៅជើងភ្នំ ។

ដានី : នៅស្វាយរមៀល?

ខន : បាទ!មានមន្ទីរកងទ័ពគេហាត់រឹកវឿន ។

ដានី : កាលហ្នឹងពូនៅកងទ័ពកន្លែងណា ពេលដែលពូនៅហាត់រឹកវឿនហ្នឹង?

ខន : នៅមន្ទីរ០៥ ។

ដានី : ០៥?

ខន : បាទ!ហៅមន្ទីរ០៥ កន្លែងបង្ហាត់រឹកវឿនកងទ័ពហ្នឹង ។

ដានី : កាលហ្នឹងពូនៅកងទ័ពតំបន់ឬកងទ័ពស្រុក?

ខន : នៅកងទ័ពតំបន់ម៉ាហាត់ ។

ដានី : បានយើងចូលទៅដល់តំបន់ហើយ បានយើងទៅហាត់?

ខន : បាទៗ!ទៅហាត់ ។

ដានី : ហាត់នៅមន្ទីរ០៥?

ខន : នៅមន្ទីរ០៥ ។

ដានី : មន្ទីរ០៥ហ្នឹងកាលហ្នឹងយើងហាត់យ៉ាងម៉េចខ្លះទៅ?

ខន : អេស៎!ហាត់លូត ហាត់ក្រាប ហាត់រត់ ហាត់បាញ់ម៉ាចប់ហ្នឹង ។

ដានី : កាលហ្នឹងហាត់រយៈពេលប៉ុន្មាន?

ខន : កាលហ្នឹងដូច១ខែឬ១ខែកន្លះនោះហាត់ ។

ដានី : ហាត់១ខែកន្លះ?

ខន ៖ បាទ!

ដានី ៖ នៅមន្ទីរ០៥ មន្ទីរហ្នឹងមន្ទីររបស់តំបន់?

ខន ៖ របស់តំបន់ ។

ដានី ៖ របស់តំបន់១៣ហ្នឹង?

ខន ៖ បាទ!រៀនហាត់ហើយគេធ្វើជីវទស្សន៍ ស្វ័យតិទានៗហើយគេធ្វើជីវទស្សន៍សំនួរគេ សួរ ។

ដានី ៖ គេសួរយ៉ាងម៉េចខ្លះទៅ?

ខន ៖ គេសួរស្មាទិទានគេថាឲ្យយើងយល់ពីកំហុសខ្លួនយើង ក្នុងការហាត់ហ្នឹងចំណុចខ្លាំងយើង អ៊ី ចំណុចខ្សោយយើងអ៊ី ។

ដានី ៖ បាទ!

ខន ៖ ហើយបើយើងខុសច្រើនអ្នកនៅជុំវិញហ្នឹងគេជួយមតិយើង តិទានយើង ពាក្យថារិះគន់ពីមុនគេហៅថាស្វ័យតិទានៗ ។

ដានី ៖ បាទ!

ខន ៖ ប៉ុនយើងឥឡូវគេថារិះគន់ ។

ដានី ៖ បាទ!

ខន ៖ បានធ្វើឲ្យមនុស្សវាមានគុណភាព ។

ដានី ៖ បាទៗ!

ខន ៖ បាទ!ស្វ័យតិទានហ្នឹងមនុស្សវាខ្សោយ ខំប្រឹងប្រែង ។

ដានី ៖ បាទ!នៅសាលា០៥ហ្នឹង កាលហ្នឹងពីណាគេជាអ្នកម៉ោបង្ហាត់យើង?

ខន ៖ អេស៎!តាខែម មន្ទីរប្រធានមន្ទីរតំបន់ហ្នឹង ។

ដានី ៖ ប្រធានមន្ទីរតំបន់?

ខន ៖ បាទ!

ដានី ៖ នៅមន្ទីរ០៥ហ្នឹង ឈ្មោះតាខែម?

ខន ៖ បាទ!ឈ្មោះតាខែម ។

ដានី ៖ តាខែម គាត់នៅណាឥឡូវ?

ខន ៖ អេស៎!អត់ដឹងទេឥឡូវ ។

ដានី ៖ បាទៗ!

ខន :	យូរហើយ ។

ដានី :	បាទ!ដល់ពេលហាត់មួយខែកន្លះហើយយ៉ាងម៉េចទៀតទៅ?

ខន :	ដល់ហាត់ហើយគេបញ្ជូនម៉ោសមរភូមិវិញម៉ោ ។

ដានី :	ម៉ោអញ្ចឹង កាលហ្នឹងពូនៅក្នុងកងណាវរៈណាកងពលណាដែរ?

ខន :	ខ្ញុំនៅវរៈ នៅ“ត៥”ជំនាន់ហ្នឹង ។

ដានី :	បាទ?

ខន :	វរៈ៥ ។

ដានី :	វរៈ៥?

ខន :	បាទ!គេហៅ“ត៥”ត១វរៈ១ ត២វរៈ២ ត៣វរៈ៣ ។

ដានី :	អ្ហូ!មានកងពលឥឡូវកាលហ្នឹង?

ខន :	ជំនាន់ហ្នឹងអត់ទាន់មានកងពលទេ មានតែវរៈសេនាធំតំបន់ហ្នឹង ។

ដានី :	បាទ!

ខន :	ដល់នៅហ្នឹងប្រហែលបាន៣-៤ខែ រំបែកអន្លុងសោមបានគេបញ្ជូនខ្ញុំម៉ោភូមិភាគ ។

ដានី :	អ្ហូ!បញ្ជូនម៉ោភូមិទៀត?

ខន :	បាទ!

ដានី :	ចូលឆ្នាំ៧៣ឬនៅហ្នឹង?

ខន :	ចូល៧៣បញ្ជូនទៅភូមិភាគ ។

ដានី :	ចូល៧៣បញ្ជូនម៉ោភូមិភាគទៀត?

ខន :	បាទ!

ដានី :	បែកអន្លុងសោមហ្នឹង?

ខន :	បែកអន្លុងសោមហើយ បើភូមិភាគគេបញ្ជូនម៉ោដើររហូតអូនអើយ ។

ដានី :	អ្ហូ!

ខន :	ដើរពី គិតទៅដើរពីត្រាំកក់ម៉ោតាមផ្លូវបរសែតកាត់ប៉ុករកាធំ ឡើងម៉ោជិតផ្លូវជាតិលេខ៤ភ្នំស្រង់ ទម្រាំមកដល់ព្រៃក្មេង មកដល់អមលាំងដើរមិនតិចថ្ងៃ ខ្លះបុកស្រូវខ្លះ បុកអង្ករវ៉ាយទម្លាក់ខ្លះយំខ្លះអីដល់ហ្នឹង អេ៎!មនោសញ្ចេតនាទាំងគេទាំងយើងយំ អាណិតអាសូរខ្លួនណាស់ រត់ទៅផ្ទះក៏មិនដឹងរត់ទៅផ្លូវណា សុទ្ធតែព្រៃអូនឯងបើដើរ រាប់ថ្ងៃ ។

ដានី ៖ ដើរពីត្រង់ណា ដំបូងចេញពីណាទៅ?

ខន ៖ តាំងពីត្រពាំង តាំងពីអន្លង់វែង ត្រពាំងធំៗ ត្រពាំងគល់ដើរម៉ោរហូតបរសែតកាត់ប្អូក រការធំ កាត់ស្ពានវែងយប់ឡើងផ្លូវលេខជាតិ៤ កាត់ផ្លូវជាតិលេខ៤រហូតដល់ភ្នំស្រួចខ្លះទេ ព្រៃក្មេងព្រៃអីរហូតទៅធ្លាក់ក្រាំងថ្មកំពង់ឆ្នាំងនេះ ដើរៗឆ្ងាយដើររាប់អាទិត្យនោះ ណា៎ ។

ដានី ៖ បាទ!

ខន ៖ ហើយបើយើងដល់ហ្នឹង យំនឹកផ្ទះរករត់ទៅផ្ទះមិនដឹងរត់ទៅតាមផ្លូវណា ។

ដានី ៖ កាលហ្នឹងពូអាយុប៉ុន្មាន?

ខន ៖ អេស៎!កាលហ្នឹងអាយុប្រហែលជា១៧-១៨អីយ៉ាងច្រើន ។

ដានី ៖ បាទ!

ខន ៖ ហើយមកដល់ហ្នឹងនៅក្រាំងស្រមរប្រហែល១ថ្ងៃ-២ថ្ងៃ គេបញ្ជូនទៅទៀតហើយ ។

ដានី ៖ ទៅណាទៀតទៅ?

ខន ៖ ទៅសមរភូមិ ។

ដានី ៖ កាលហ្នឹងពូមានដូចថានៅក្នុងហ្នឹងមានកងពល មានអីត្រឹមត្រូវដែរ?

ខន ៖ អេស៎!មានកងពលគេត្រឹមត្រូវ ។

ដានី ៖ កាលហ្នឹងពូនៅក្នុង?

ខន ៖ ខ្ញុំនៅក្នុងកងពលទី១ ។

ដានី ៖ កងបលទី១?

ខន ៖ បាទ!

ដានី ៖ ពូមានតួនាទីអីដែរកាលហ្នឹង?

ខន ៖ កាលហ្នឹងខ្ញុំកាន់«t-o»ជំនាន់ហ្នឹង ។

ដានី ៖ កាន់«t-o»?

ខន ៖ បាទ!

ដានី ៖ «to»យើងនៅជាមួយកងពលម៉ងឬក៏នៅ?

ខន ៖ ខ្ញុំនៅជាមួយវរៈសេនាធំគេ ។

ដានី ៖ នៅវរៈសេនាធំទីប៉ុន្មានទៅ?

ខន ៖ នៅវរៈសេនាធំ១៦ ។

ដានី ៖ ១៦?

ខន ៖ បាទ!

ដានី ៖ ពីណាគេប្រធានវរៈសេនាធំ?

ខន ៖ ប្រធានហ្នឹងបង នឹម ។

ដានី ៖ បាទ?

ខន ៖ បង នឹម គាត់ស្លាប់បាត់ហើយ ។

ដានី ៖ ចុះកងពលទី១?

ខន ៖ កងពលទី១តា សឿង ។

ដានី ៖ តាសឿង?

ខន ៖ តាសឿងក៏ស្លាប់បាត់ដែរ តាសឿងកូនតាម៉ុក អេស៎!តាសឿងដូចធំជាងតាម៉ុកឬតូចជាងតាម៉ុកទេ ។

ដានី ៖ តាម៉ុកគាត់បងប្អូន?

ខន ៖ បងប្អូនគាត់សុទ្ធតែអ្នកត្រពាំងធំ ។

ដានី ៖ ពីណាទៀតបន្ទាប់ពីតាសឿង ក្នុងគណៈកងពល?

ខន ៖ បន្ទាប់ពីតាសឿង ទៀតអត់ដឹងទេ ដឹងតែតាសឿងៗ ។

ដានី ៖ អញ្ចឹងកាលហ្នឹងកងពលទី១ នៅក្នុងភូមិភាគនិរតីឬនៅភូមិភាគពិសេស?

ខន ៖ ភូមិភាគ អេស៎!ជំនាន់ហ្នឹងភូមិភាគនិរតី ដល់បែកភ្នំពេញគេបែកគ្នាទៅភូមិភាគបញ្ចឹម ។

ដានី ៖ បាទ!

ខន ៖ ដល់ភូមិភាគបញ្ចឹមហើយ នៅច្រើនដំណាក់កាលទៀត ដល់យើងសម័យ៧៨នេះប្ដូរទៀតហើយខ្ញុំ គេប្ដូរទៅកងពលមជ្ឈិម ទៅមជ្ឈិមនោះទៀត ។

ដានី ៖ បាទ!អញ្ចឹងកាលនោះពួដើរទៅដល់កន្ទែងក្រាំងស្រមរអី ខាងកំពង់ឆ្នាំងចូលទៅកងពលទី១ហើយ កាលហ្នឹងយើងយ៉ាងម៉េចទៅ យើងធ្វើសកម្មភាពយើងទៅវ៉ៃ?

ខន ៖ អាហ្នឹងគេបញ្ជូនយើងម៉ោសមរភូមិអូន ។

ដានី ៖ សមរភូមិណាទៅ?

ខន ៖ សមរភូមិម៉ោមុំវត្តភ្នំ នៅមុំត្រពាំងត្នោតជិតភ្នំពេញ ទួលលាបអីហ្នឹង ។

ដានី ៖ ទួលលាប?

ខន : បាទ!កងទ័ពណាដែលស្លាប់ច្រើនគេបញ្ជូនយើងទៅអង្គភាពហ្នឹង ដូច្នេះទៅដល់ហ្នឹងមៅរាប់រយគេចែក វរៈសេនាធំមៅកងពលហ្នឹង ប៉ុននេះទៅវរៈសេនាធំនេះ ប៉ុននេះទៅវរៈសេនាធំនេះ ប៉ុននេះទៅវរៈសេនាធំនោះគេចែកគ្នា ។

ដានី : បាទ!

ខន : បាទ!ចែកគ្នា វរៈសេនាធំនោះគេចែកតាមវរៈសេនាតូចទៀត វរៈសេនាតូចគេចែកតាមអនុសេនាធំទៀត ។

ដានី : បាទៗ!

ខន : អនុសេនាធំហ្នឹងគេចែកតាមអនុសេនាតូចទៀត ហើយដល់ហ្នឹងគេសួរគេនេះយើងដែរ គេធ្វើប្រវត្តិរូបយើង យើងធ្លាប់ធ្វើការធ្វើសកម្មភាពអី គេមើលតាមយើងហើយគេជ្រើសរើសឲ្យកន្លែងឲ្យអីនៅ ។

ដានី : ចុះពុកាលហ្នឹងដល់ពេលពូម៉ោកាន់ខាង“t-o”កាលហ្នឹង ពូមានបានរៀនខាង“to”អីយ៉ាងម៉េចប្អត់?

ខន : ខ្ញុំបានរៀនដែរ ខ្ញុំរៀន“t-o”ក៏ខ្ញុំរៀន ដែនទីក៏ខ្ញុំរៀន ត្រីវិស័យក៏ខ្ញុំរៀន កែវយិតក៏ខ្ញុំរៀន ។

ដានី : រៀនពីអ្នកណាម៉ោ?

ខន : ខ្ញុំរៀនពីគេបង្រៀន អ្នកធំៗបង្រៀន ចិនបង្រៀនឆ្នាំនេះហើយៗឆ្នាំដែលយួនចូលហើយបានចិនបង្រៀន ។

ដានី : បាទ!ប៉ុន្តែប៉ុនពេលហ្នឹង ពេលដែលពូហាត់ពីសាលា០៥ពីនេះហើយ ពេលដែលយើងចូលម៉ោចូលដល់កន្លែង“t-o”ហ្នឹងកាលហ្នឹងយើងអត់ទាន់មានជំនាញខាង“t-o”ហ្នឹងទេ?

ខន : អត់ទាន់មានជំនាញទេ ។

ដានី : ដល់ពេលអញ្ចឹងយើងត្រូវរៀនអីយ៉ាងម៉េចដើម្បីចេះប្រើ“t-o”ហ្នឹង?

ខន : អ៊ូ!“t-o”វេទនាណាស់អូន “t-o”ពេលកាន់ធ្ងន់ណាស់ C25?

ដានី : ធំ?

ខន : ធំ ។

ដានី : ស្ពាយខ្នងអីម៉េចអាហ្នឹង?

ខន ៈ ស្តាយខ្លួនវាមាន“t-o”ផង វាមានត្រីវិស័យផង វាមានកែវយិតផង កាន់“t-o”ហ្នឹង ពិបាកណាស់ខបសត្ត ។

ដានី ៈ បាទ!

ខន ៈ បើយើងហៅកាំភ្លើងធំវ៉ៃដាន់គេ គេថាយើងក្បត់ វ៉ៃហួសគេឆ្ងាយវាពិបាកទៀត អ្ហ៎!ពិបាកមានគ្រោះថ្នាក់ណាស់ ដល់ពេលឈ្នះគេស្រួល សប្បាយ ។

ដានី ៈ បាទ!

ខន ៈ ដល់ពេលចាញ់គេតែចោលអីបន្តិចពិបាកទៀត ។

ដានី ៈ អ្ហ៎!អញ្ចឹង?

ខន ៈ បាទ!វេទនាណាស់ជីវិតទាហានអាកំពូជកម្មរទេសហូរនេះវេទនាណាស់អូន ។

ដានី ៈ បាទ!

ខន ៈ ទៅក៏ធ្ងន់ ម៉ោក៏ធ្ងន់អត់បានអីគេស៊ីទេអត់មានទេ ។

ដានី ៈ បាទ!តែពូនៅដាប់វរៈសេនាធំតែម្តង?

ខន ៈ នៅដាប់វរៈសេនាធំ ដល់អញ្ចឹងយើងនៅឆ្ងាយពីគេដែរ ។

ដានី ៈ នេះយើងនិយាយហ្នឹងដូចថានិយាយនៅវរៈសេនាធំគេបញ្ជាអីយ៉ាងម៉េច?

ខន ៈ បាទ!គេបញ្ជា ។

ដានី ៈ ហើយយើងនិយាយទៅ?

ខន ៈ បាទ!យើងនិយាយទៅ ។

ដានី ៈ គ្រប់សមរភូមិពេលវ៉ៃ?

ខន ៈ គ្រប់សមរភូមិ ។

ដានី ៈ អញ្ចឹងពូនៅពីឆ្នាំ៧៣ហ្នឹងរហូតដល់ឆ្នាំបែកភ្នំពេញនៅ?

ខន ៈ បាទ!បែកភ្នំពេញហ្នឹងបានខ្ញុំទៅកន្លែងផ្សេងទៀត ។

ដានី ៈ បាទ!ប៉ុន្តែនៅសមរភូមិខាងកំពង់ឆ្នាំង ទួលលាប?

ខន ៈ បាទ!បែក៧៣ហ្នឹងម៉ោសមរភូមិជុំវិញភ្នំពេញរហូត ។

ដានី ៈ ជុំវិញភ្នំពេញ?

ខន ៈ បាទ!នៅម្តុំត្រពាំងត្នោត នៅភ្នំប្រសិទ្ធ ត្រពាំងព្រែកជិតៗភ្នំពេញហ្នឹង ។

ដានី ៈ អ្ហ៎!ដាប់ ។

ខន : មិនមែនថ្នល់រទេសភើងទេ ជិតៗភ្នំពេញហ្នឹង ។

ដានី : យើងនៅហ្នឹងដាច់ៗ ?

ខន : នៅបាតដឹងហ្នឹង ជិតៗគ្នាហ្នឹង ជិតកប់ជុំវិញហ្នឹងទាំងអស់ ។

ដានី : ពួកខាងភូមិភាគ៣០៤ហ្នឹងម៉ោនៅជិតហ្នឹងដែរ?

ខន : ខ្ញុំនៅកងពលទី១ នៅនៅជិតខត្តុងនោះ ពេលសម្រាកទៅសម្រាកខត្តុង ។

ដានី : បាទ!

ខន : ខត្តុងក៏ពួកខ្ញុំនៅដែរ បាននៅខត្តុងដែរ ។

ដានី : បាទៗ!

ខន : នៅម្តុំក្រាំងស្រមរ នៅស្វាយចេក នៅសម្រាកនៅហ្នឹងទីតាំងគេនៅហ្នឹង ។

ដានី : កាលហ្នឹងពូអត់មានត្រូវរបួសត្រូវអីទេ?

ខន : អត់ត្រូវរបួសទេ ខ្ញុំត្រូវរបួសជំនាន់នេះនៅ៧៨នេះម្តងដែរ ។

ដានី : បាទ!អញ្ចឹងពេលបែកភ្នំពេញឆ្នាំ៧៥ហ្នឹង ដែលយើងរំដោះបានភ្នំពេញពេលកងទ័ពចូលទៅ កាលហ្នឹងយ៉ាងម៉េចដែរកងពលរបស់?

ខន : ពេលដែលបែកភ្នំពេញហើយវេទនាណាស់អូនអើយ ពិបាកណាស់ពេលដែលបែកភ្នំពេញហើយគេបញ្ជូនទៅធ្វើថ្នល់រទេសភ្លើងដល់កំពត ។

ដានី : កងពល?

ខន : បាទ!

ដានី : កងពលទី១ហ្នឹង?

ខន : កងពលទី១ ។ អ្ហូ!ធ្វើថ្នល់ជាតិ អាថ្នល់ដែលដាច់ៗ មេហោ៧២កន្ទាក់ឬក៏គេកាត់ផ្តាច់មិនឲ្យឡានម៉ោគេធ្វើថ្នល់ជាតិ ។

ដានី : បាទ!

ខន : ធ្វើថ្នល់ជាតិហើយ គេបញ្ជូនទៅធ្វើថ្នល់រទេសភ្លើងនៅកំពតកំពង់ត្រាច ។

ដានី : បាទ!

ខន : ធ្វើថ្នល់រទេសភ្លើងហើយ គេបញ្ជូនម៉ោធ្វើស្រែកាប់នឹងចបនៅចោមចៅ ធ្វើស្រែកាប់នឹងចប អស់ពីធ្វើស្រែកាប់នឹងចបចោមចៅគេបញ្ជូនឲ្យម៉ោជួយធ្វើស្រែប្រជាជននៅកំពង់ឆ្នាំង បាយមួយថ្ងៃតែ១កំប៉ុងទេម៉ាវែក បបរមួយថ្ងៃវាស់ល្ងាច ។

ដានី ៖ កាលហ្នឹងដល់ពេលយើងបែកភ្នំពេញឆ្នាំ៧៥ហើយ កងពលពូកងពលទី១ហ្នឹងមានប្ដូរឈ្មោះមានផ្លាស់មានឡើង?

ខន ៖ អត់ទាន់មានផ្លាស់ទេនៅកងពលទី១ដដែល ។

ដានី ៖ កងពលទី១ចំណុះរបស់ភូមិភាគឬរបស់សេនាធិការ?

ខន ៖ ទេអត់ដឹងទេជំនាន់ហ្នឹងព្រោះគេអ្នកធំ កងពលភូមិភាគនិរតីហ្នឹងម៉ង ។

ដានី ៖ ភូមិភាគនិរតី?

ខន ៖ បាទ!

ដានី ៖ មិនមែនភូមិភាគបញ្ចឹមទេ?

ខន ៖ មិនមែនភូមិភាគបញ្ចឹមទេ ។

ដានី ៖ ភូមិភាគនិរតី?

ខន ៖ បាទ!

ដានី ៖ បាទ!អញ្ចឹងកងពលហ្នឹងអត់បានចូលភ្នំពេញទេ?

ខន ៖ ដល់បែកភ្នំពេញហើយ បានមាននិរតីបានមានបញ្ចឹម ។

ដានី ៖ បាទ!

ខន ៖ ពីមុនមាននិរតីតែមួយទេ ។

ដានី ៖ បាទៗ!អញ្ចឹងដល់ពេលមានបញ្ចឹមហើយនឹងនិរតីហ្នឹង ប៉ុន្តែកងពលរបស់ពូនៅខាងនិរតីទេ?

ខន ៖ នៅខាងបញ្ចឹម ។

ដានី ៖ ខាងបញ្ចឹម?

ខន ៖ បាទ!

ដានី ៖ យើងៗបែកភ្នំពេញហើយ យើងអត់បានចូលទៅភ្នំពេញទេ យើងចេញម៉ោក្រៅ វិញ?

ខន ៖ គេឲ្យនៅក្រៅ គេអត់ឲ្យនៅភ្នំពេញណា៎ ។

ដានី ៖ គេអត់ឲ្យម៉ោភ្នំពេញទេ?

ខន ៖ បាទ!

ដានី ៖ ចុះពូនៅកាន់“t-o”ដដែរឬក៏ផ្លាស់ប្ដូរ?

ខន ៖ ដល់ជំនាន់ហ្នឹងគេគ្មាននៅកាន់“t-o”ទៀត គេឲ្យនៅធ្វើស្រែទាំងអស់គ្នា ។

ដានី ៖ ធ្វើស្រែ?

ខន ៖ បាទ!

ដានី ៖ យើងម៉ោធ្វើថ្នល់ម៉ោជួសជុលធ្វើថ្នល់នៅកំពត ធ្វើផ្លូវរទេសភ្លើងហ្នឹង?

ខន ៖ បាទ!អាហ្នឹងធ្វើផ្លូវរទេសភ្លើងយើងសែងដីដាក់តាមថ្នល់លុបបំពេញទំនប់ដាច់ៗហ្នឹង ។

ដានី ៖ ធ្វើហើយរយៈពេលប៉ុន្មានទៅ?

ខន ៖ ធ្វើបាន២ខែៗ ប្រហែល៤ខែសរុបទៅ ម៉ាកងពលៗគ្នាច្រើន ។

ដានី ៖ បាទ!ហើយម៉ោធ្វើថ្នល់រទេសភ្លើងវិញ?

ខន ៖ បាទ!ម៉ោធ្វើថ្នល់រទេសភ្លើងហើយ យើងម៉ោពេញវិញគេឲ្យម៉ោ ។

ដានី ៖ ម៉ោនៅពេញវិញ?

ខន ៖ ម៉ោនៅចោមចៅ ធ្វើស្រែកាប់នឹងចបខាងលិចពេញ ។

ដានី ៖ អ៊ូ!បាទ ។

ខន ៖ ទាល់តែធ្វើស្រែហ្នឹងហើយ គេបញ្ជូនម៉ោលង្វែក ។

ដានី ៖ ធ្វើស្រែបានយូទេ?

ខន ៖ ធ្វើស្រែអត់បានយូទេ គ្រាន់តែធ្វើស្រែហើយគេបញ្ជូនមកទៀតហើយ ។

ដានី ៖ អញ្ចឹងមកធ្វើថ្នល់រទេះភ្លើងក៏អត់យូដែរ?

ខន ៖ អត់យូទេ ។

ដានី ៖ ក្នុងឆ្នាំណា?

ខន ៖ ធ្វើថ្នល់រទេះទេះភ្លើង១៧មេសា ឆ្នាំ៧៥ ចប់ហើយទៅនោះភ្លាម អត់មានបានសម្រាកបន្តិចទេ ។

ដានី ៖ ដល់ពេលមកធ្វើស្រែបានបន្តិចហើយយើងទៅទៀត?

ខន ៖ ហើយគេបញ្ជូនយើងមកលង្វែកទៀត ។

ដានី ៖ ឆ្នាំណាមកលង្វែកហ្នឹង?

ខន ៖ មកលង្វែកឆ្នាំ៧៦ ។

ដានី ៖ ធ្វើអីនៅលង្វែក?

ខន ៖ មកលង្វែកម៉ោធ្វើស្រែដែរ តែមកដល់ហ្នឹងវេទនាណាស់ ធ្វើស្រែនៅក្រាំងពន្លៃ ។

ដានី ៖ ចុះយើងអត់មានបានហូបអីគ្រប់គ្រាន់ទេកាលហ្នឹង?

ខន ៈ គេឲ្យយើងគ្រប់គ្រាន់តែយើងអត់បានហូបឆ្អែត គេឲ្យតែបបរ ។

ដានី ៈ អញ្ចឹងកងទ័ពគេឲ្យហូបបបរដែរ?

ខន ៈ កងទ័ពហ្នឹងបបរ តែមេគេមិនដឹងម៉េចយើងអត់ដឹងដែរ ហូបតែត្នោតទំនោលផ្អែក ហើយក្រអៅឈូកទេ កុំតែបានបឹងឈូកនៅកន្លែងកែងលផ្អែកហ្នឹងទេកុំអីងាប់ច្រើន ណាស់ ជំនាន់ហ្នឹងហេវពេកលួចដំឡូងគេ គេឲ្យស៊ី ដោះដំឡូងមួយគុម្ពគេឲ្យស៊ី អ្នកណាស៊ីមិនអស់គេវៃចោល អ្នកណាលួចស្ករស៊ីគេឲ្យស៊ីស្ករម៉ៅប៉ោតម្នាក់ឯង អ្នក ណាលួចស៊ីអស់ស្ករម៉ៅប៉ោត ហើយដំឡូងមីអ្នកណាស៊ីអស់ម៉ាគុម្ពម្នាក់ឯង ។

ដានី ៈ បាទ!

ខន ៈ ជំនាន់ហ្នឹងដឹងខាងលើម៉េចយើងអត់ដឹង ប៉ុនជាន់ក្រោមគេឲ្យស៊ីបបរ កងទ័ពក៏ហាមដែរ តែសុខទុក្ខប្រជាជនយ៉ាងម៉េចយើងអត់ដឹងទេ ។

ដានី ៈ អត់ដឹងដែរ?

ខន ៈ បាទ!

ដានី ៈ បាទ!ចុះពូមានតួនាទី មានឋានៈអីដែរ?

ខន ៈ ជំនាន់ហ្នឹងខ្ញុំកងតូចពី៧៥ហ្នឹងម៉ោ ។

ដានី ៈ ៧៥ ម៉ោយើងបានជាតួនាទីជាកងតូច?

ខន ៈ បាទ!

ដានី ៈ កងតូចហ្នឹងអនុសេនាតូច?

ខន ៈ អនុសេនាតូច ។

ដានី ៈ បាទ!អញ្ចឹងដល់ពេលនៅលផ្អែក នៅក្រាំងពន្លៃហ្នឹងបានយូរទេ?

ខន ៈ នៅក្រាំងពន្លៃហ្នឹងអត់បានយូរទេ ដល់ឆ្នាំ៧០ ដាច់៧៦ចូល៧៧នោះ គេឲ្យប្រមូល អីវ៉ែអីវ៉ាន់អីយកម៉ោភ្នំពេញខ្ញុំស្មានតែគេវៃចោលអស់ហើយ

មានចបមានបង្គីរមានកាំភ្លើងមកដល់ ភ្នំពេញហ្នឹងៗគេឲ្យហូបបាយ ហូបបាយ ហើយគេឲ្យតំរង់ជួរគេឲ្យលាងចានខ្ញុំស្មានគេវៃ ចោលបាត់ហើយយប់ បានយប់តំរង់ វៃគេដឹកឡានៗម៉ោអញបែបងាប់ហើយ ដឹក ឡានដិះឡានមិនដឹងត្រង់ណាទេ សង្ស័យ មុខវាំងជំនាន់ហ្នឹងយប់ ដល់ហើយគេឲ្យឡើង កប៉ាល់ ជិះកប៉ាល់ម៉ាយប់ទល់ភ្លឺ បានភ្លឺ ឡើងដល់ក្របេះៗ ។

ដានី ៖ ចុះម៉េចជំនាន់នោះពូធ្លាប់ឃើញគេវ៉ៃ គេចាប់មនុស្សគេវ៉ៃចោលបានយើងដឹងថាគេវ៉ៃចោល?

ខន ៖ ខ្ញុំធ្លាប់ឃើញគេចាប់ៗ ។

ដានី ៖ ឃើញគេចាប់?

ខន ៖ បាទ!

ដានី ៖ ចាប់នៅណានៅក្នុងកងពល?

ខន ៖ ធ្លាប់ឃើញគេចាប់ច្រើនគ្នា ឲ្យតែបាត់ខ្លួនដឹងតែគេចាប់ហើយ ។

ដានី ៖ ក្នុងកងពលហ្នឹង?

ខន ៖ បាទ! ដល់អញ្ចឹងគេបញ្ជូនម៉ោក្រចេះ ។

ដានី ៖ ចុះតាសឿង គាត់នៅប្រធានកងពលហ្នឹង?

ខន ៖ តាសឿង គាត់ប្រធានកងពល បញ្ជូនខ្ញុំចេញពីហ្នឹង តាសឿង គេបញ្ជូនម៉ោ ។

ដានី ៖ បញ្ជូនទៅណា?

ខន ៖ គេបញ្ជូនទៅក្រចេះហ្នឹង ដល់ឡើងពីក្រចេះហ្នឹងមាំថ្ងៃទៀតមកដល់ព្រំដែន ។

ដានី ៖ ព្រំដែនណា?

ខន ៖ ដល់ស្នួលនោះ ស្រុកស្នួលនោះ ហួសស្នួលទៀត ។

ដានី ៖ បាទ!

ខន ៖ ជាប់យួននោះ ។

ដានី ៖ បាទ!គេនៅធ្វើអីហ្នឹង?

ខន ៖ គេនៅធ្វើ កាលហ្នឹងកងទ័ពគេឲ្យកាំភ្លើងហ្នឹង អត់ទាន់ឲ្យកាំភ្លើងផង មានដងវែកមានចប អីដល់យួនវ៉ៃគ្នាចាប់ផ្ដើមវ៉ៃបានគេឲ្យកាំភ្លើង ។

ដានី ៖ អ្ហូ!ហ្នឹងឆ្នាំ៧៧ហ្នឹង?

ខន ៖ ៧៧ហ្នឹង ចុង៧៧-៧៨ហើយ ។

ដានី ៖ ចុះតាសឿង គេនៅមិនទាន់ចាប់គាត់ឬគេចាប់ហើយ?

ខន ៖ តាសឿង កាលរត់ម៉ោ តាសឿងកាលរត់៧៩នៅទេ ។

ដានី ៖ អ្ហូ!

ខន ៖ បែបទើបស្លាប់ត្រឹមណាទេអត់ដឹងដែរ ។

ដានី : អញ្ជឹងកាលទៅក្របេះទៅអីហ្នឹង តាសឿងទៅដែរ?
ខន : តាសឿង អត់ទេ ។
ដានី : តាសឿងអត់ទៅទេ?
ខន : បាទ!
ដានី : អាហ្នឹងយើងទៅ ទៅយ៉ាងម៉េចទៅក្របេះហ្នឹង?
ខន : ទៅហ្នឹងគេបញ្ជូនទៅ ។
ដានី : ជាកងទ័ព ជាកងពលទី១ដដែលឬ?
ខន : អត់ទេ!ជាកងពលផ្សេង ។
ដានី : កងពលយ៉ាងម៉េចទៅកាលហ្នឹង?
ខន : កងពលមជ្ឈិម ។
ដានី : កងពលមជ្ឈិម?
ខន : បាទ!មជ្ឈិមគេគ្រប់គ្រង មិនមែនតា សឿងគ្រប់គ្រងណា ។
ដានី : មិនមែនតាសឿង ទៀតទេ?
ខន : បាទ!
ដានី : អាហ្នឹងដល់ពេលពូម៉ោ គេបញ្ជូនម៉ោជិះកប៉ាល់អីឡើងទៅក្របេះហ្នឹងកងពលផ្សេង ហ្នឹង?
ខន : កងពលផ្សេង ។
ដានី : កងពលអីទៅអាហ្នឹង?
ខន : អាហ្នឹងកងពល១១៧/របស់មជ្ឈិមទេ ។
ដានី : កងពល១១៧/របស់មជ្ឈិម?
ខន : បាទ!
ដានី : អញ្ជឹងសមាសនៅក្នុងកងពលទី១ហ្នឹងគេយកម៉ោទាំងអស់មកធ្វើការនៅហ្នឹង?
ខន : អត់ទេ!គេយកម៉ោ មិនដឹងយកម៉ោរបៀបម៉េចទេគេបញ្ជូនម៉ោ ។
ដានី : បញ្ជូនម៉ោប៉ុន្មានទៅ?
ខន : បញ្ជូនម៉ោជាចំរុះច្រើនតាមតំបន់ផងតាមកងពលផង ។
ដានី : អ្ហូ!អញ្ជឹងកងពលទី១ នៅកងពលទី១ដដែល ប៉ុន្តែគេបញ្ជូនម៉ាចំនួនម៉ោ?
ខន : បាទ!គេបញ្ជូនម៉ាចំនួនម៉ោ ។

ដានី :	ម៉ាចំនួនម៉ោ គេដកម៉ាចំនួនដឹងថាគេដកម៉ោប៉ុន្មានទេ?

ខន :	អត់ដឹងប៉ុន្មានផង ។

ដានី :	ចុះវរៈរបស់ពូ វរៈសេនាធំរបស់ពូ?

ខន :	វរៈម៉ោទាំងអស់ប៉ុនផ្សេងៗគ្នា ។

ដានី :	ចុះឈ្មោះ នឹម ថាប្រធានវរៈសេនាធំគាត់ទៅដែរឬអត់ទេ?

ខន :	ឈ្មោះ នឹម ប្រធានវរៈសេនាធំក៏គាត់ទៅហ្នឹង ។

ដានី :	ទៅណា?

ខន :	នៅក្រចេះហ្នឹងដែរ ។

ដានី :	គាត់ម៉ោក្រចេះដែរ?

ខន :	ក្រចេះដែរ ។

ដានី :	កាលហ្នឹងគាត់មានតួនាទីនៅវរៈដដែលឬឡើងជាកងពល?

ខន :	វរៈសេនាធំហ្នឹងគាត់នៅដដែលទេ អត់ទាន់ឡើងទេប៉ុនដល់៧៩អីបានគាត់ឡើងមើល៍ ទៅ ។

ដានី :	បាទ!អញ្ចឹងម៉ោកងពល១១៧ហ្នឹងពីណាគេប្រធាន?

ខន :	លាង ប្រធាន អ្ហ៊ូ!តារុម ប្រធាន បងរុម ហើយលាង ។

ដានី :	តារុមហ្នឹងគាត់នៅណា?

ខន :	បងរុមហ្នឹងស្រុកកំណើតគាត់នៅតាកែវដែរ ។

ដានី :	នៅតាកែវ?

ខន :	បាទ!លាងហ្នឹងក៏នៅតាកែវ គាត់សិស្សជំនិតរបស់តាសឿង ។

ដានី :	ជមនិតរបស់តាសឿង?

ខន :	បាទ!កូនចៅរបស់តាសឿង ។

ដានី :	បាទ!អញ្ចឹងនៅពេលទៅដល់ក្រចេះទៅដល់ហ្នឹង កងពលរបស់ពូទៅខាងស្នួលដែរ?

ខន :	ទៅខាងស្នួល ហួសស្នួលទៀតនៅម្តុំទួលគ្រោះទួលអីនោះ ។

ដានី :	ទួលគ្រោះ?

ខន :	ជាប់ព្រំដែននោះ ។

ដានី :	អាហ្នឹងកងពលរបស់មជ្ឈឹម?

ខន :	កងពល១១៧របស់មជ្ឈឹម ។

ដានី ៖ របស់មជ្ឈឹម?

ខន ៖ បាទ!

ដានី ៖ យ៉ាំងម៉េចទៅដល់ពេលហ្នឹងវ៉ើ?

ខន ៖ ទៅដល់ហ្នឹងហូបចុកអីដូចជាបានឆ្អែត ប៉ុន្ដែវាទាស់បន្ដិច គ្រាន់តែថាប្រឆាំងគេអត់បាន ទេ បញ្ហាធ្វើម៉េចត្រូវធ្វើអញ្ចឹងអត់បានទេជិនាន់ហ្នឹង ។

ដានី ៖ បញ្ហា ខបមាថាគេប្រាប់ឲ្យធ្វើអីយើងត្រូវតែធ្វើហ្នឹងអត់មានតវ៉ាទេ?

ខន ៖ អត់បានតវ៉ាអី អត់មានសិទ្ធិអីតវ៉ាទេ អត់ទេ ។

ដានី ៖ កាលហ្នឹងពូមានដែលតវ៉ាគេទេ?

ខន ៖ អត់ហានទេ តវ៉ាបាត់ខ្លួនឥឡូវហ្នឹងឲ្យតែហានតវ៉ា ។

ដានី ៖ ប៉ុន្ដែមានអ្នកតវ៉ាហើយបាត់ខ្លួនពូមានឃើញអញ្ចឹងដែរឬអត់ បានជាពូ?

ខន ៖ ធ្លាប់ឃើញបងប្អូនតវ៉ាភាគច្រើនវាបាត់ខ្លួន បងប្អូនខ្លះហេវខ្វាំងលួចនេះលួចនោះអីទៅ ហូបជិនាន់នៅកងពលនិរតី ។

ដានី ៖ បាទ!

ខន ៖ ទៅនោះអត់អ្នកណាលួចទេ ទៅដល់ក្រចេះសំបូរអីហូបណាស់ ។

ដានី ៖ អ៊ូ!

ខន ៖ ផ្លែឈើក៏សំបូរ អីក៏សំបូរនៅក្រចេះវាអត់ៗទេ ទោះក៏វង្វេង២-៣ថ្ងៃក៏អត់ស្លាប់ ដែរ ។

ដានី ៖ មានផ្លែអីទៀតទេ?

ខន ៖ ស្រុកហ្នឹងមានធុរេន មានសាវម៉ៅ មានអំពៅ មានដំឡូងមិនដូចស្រុកយើងទេ ស្រុក នោះសំបូរណាស់ស្រុកក្រចេះ ។

ដានី ៖ អ៊ូ!អញ្ចឹង?

ខន ៖ បាទ!អត់ខ្វះទេសុទ្ធតែព្រៃ ។

ដានី ៖ សត្វព្រៃសំបូរទៀត?

ខន ៖ សត្វព្រៃរឹតែសំបូរទៀត ស្រុកខេត្តក្រចេះសំបូរណាស់ ។

ដានី ៖ អ៊ូ!មានម្ហូបអី ម្ហូបយើង?

ខន ៖ សំបូរណាស់ទោះវង្វេង៨-១០ថ្ងៃក៏អត់ស្លាប់ដែរ ស្រុកក្រចេះអត់ដូចយើងខុសពី ស្រុកយើងនេះ ។

ដានី : ចុះប៉ុនយើងទៅដល់នោះយើងវ៉ៃអីវ៉ៃជាមួយយួនយ៉ាងម៉េចទៅ?

ខន : ដំបូងមិនទាន់បានវ៉ៃអី ទៅធ្វើស្រែធ្វើអីកាលទៅដំបូង ។

ដានី : បាទ!

ខន : បាទ!នៅជិតព្រំដែនយើងស្ទូងអញ្ចឹងព្រឹកហ្នឹងយួនមកដក យើងស្ទូងវិញយូរៗវាអាច ឈ្លោះគ្នាខឹង តែខឹងបាញ់គ្នាហើយៗ ។

ដានី : បាទ!

ខន : អ្នកណាទ្រាំបានយើងស្ទូងវាដករបស់យើង ។

ដានី : បាទ!

ខន : យូរៗហែងដករបស់អញ អញបាញ់ហែងមើល៉ ទំនាស់គ្នាចុះឡើងដំបូងយួនវាយកបារី យកអីមកដូរ យើងមកដីកកណ្ដុរ កាប់អាស្សីពីយើង ។

ដានី : បាទ!

ខន : អស្សីដីវាមានតែវាអត់ដីកទេ វាអត់កាប់ទេ វាកាប់ដីយើង កណ្ដុរដីវាមានក៏វាអត់ដីក ដែរវាសុខចិត្តយកពីដីវាម៉ោ វាអញ្ចឹង ។

ដានី : ម៉េចអញ្ចឹង?

ខន : អត់ដឹងយ៉ាងម៉េចដែរ ។

ដានី : យើងបេះតែឲ្យវាៗទៅ?

ខន : យើងបេះតែឲ្យៗវា យើងឲ្យជាធម្មតា ។

ដានី : បាទ!

ខន : បាទ!យូរៗទៅទំនាស់គ្នារឿងស្ទូងរឿងដកតិចតួចបានបាញ់គ្នាទៅជារឿងធំទៅ ។

ដានី : បាទ!ដល់ពេលរឿងធំបាញ់គ្នាមែនទែនធ្វើម៉េចទៅ?

ខន : បាញ់គ្នាមែនទែនដេញយើងតែមួយថ្ងៃរត់ធ្លាក់ដីប្រហែលជា៥០-៦០គីឡូនោះ ។

ដានី : ហា៎!ម៉េចអញ្ចឹងបានយើងអត់?

ខន : ចុះយើងដំបូងយើងមានអាវុធអីណាបើគេដកយកអស់ហើយ មានតែកាំភ្លើងសេៗតែ តិចៗហ្នឹង ហើយវាសុទ្ធតែ«BM»សុទ្ធតែវីងៗម៉ៅ វាដេញមួយថ្ងៃរត់ប្រហែល៣០ គីឡូខ្ញុំប្រាប់នោះ ជិតៗដល់ក្របេះនោះ ។

ដានី : ជិតដល់ក្របេះ?

ខន :	បាទ!

ដានី :	ពេលណាហ្នឹង?

ខន :	ឆ្នាំចុងជិត៧៩ហើយ ។

ដានី :	ជិតឆ្នាំ៧៩ហើយ?

ខន :	បាទ!ជិត ៧៩ហើយ ។

ដានី :	អញ្ចឹងអត់មានបានវ៉ៃតែ១-២ដងទេអញ្ចឹង អត់មានបានវ៉ៃច្រើនទេ?

ខន :	បានវ៉ៃច្រើនដែរហ្នឹង ប៉ុនវ៉ៃភាគច្រើនយើងវ៉ៃ ភាគច្រើនវ៉ៃអត់ឈ្នះគេទេភាគច្រើន ។

ដានី :	អត់ឈ្នះគេភាគច្រើន?

ខន :	បាទ!ចំនុចខ្សោយរបស់យើង យើងទ័ពនៅមុខដូចអូនឯងអញ្ចឹង គេវ៉ៃកន្លែងបាយអស់ហើយ ហើយទ័ពមុខនាំម៉េចបាន ។

ដានី :	បាទ!

ខន :	វ៉ៃបានដោយសារមានកម្លាំងពេទ្យ មានបាយនៅខាងក្រោយហូប មានមន្ទីរពេទ្យ ។

ដានី :	បាទ!

ខន :	ចុះបើពេទ្យរត់មុនទាហានទៀត ទាហាននៅម៉េចបាន អូនឯងជឿមិនជឿ ។

ដានី :	ខ្ញុំអត់ទាន់ផង ខ្ញុំអត់ធ្លាប់?

ខន :	អូនឯង ដូចថាខ្ញុំធ្វើទាហាននេះ ចុះបើកន្លែងបាយ ឆ្នាំងបាយយើងអាសម្រាប់ឲ្យអាអ្នកមុខហ្នឹងហូប ចុះបើអត់បាយហូបអូនឯងនៅម៉េចបាន ហើយបើមានរបួសទៅដេកពេទ្យនៅណា ។

ដានី :	ចុះម៉េចខាងក្រោយទៅរត់មុនខាងមុខអញ្ចឹង?

ខន :	អាហ្នឹងវាសង្គ្រាមវាយុទ្ធសាស្ត្រយុទ្ធវិធីក្នុងការវ៉ៃអាហ្នឹងវាពិបាកណាស់អូនៗ ។

ដានី :	បាទ!ដល់ពេលហ្នឹងពូត្រូវរបួសឬនៅ?

ខន :	នៅទេ ។

ដានី :	នៅទេ?

ខន :	បាទ! នៅទេ ដល់៧៩បានខ្ញុំត្រូវរបួស ។

ដានី :	បាទ!ដល់ពេលអញ្ចឹងដល់ពេលនៅក្រចេះចុងឆ្នាំ៧៩ហ្នឹង?

ខន :	ចុង៧៩ហ្នឹងខ្ញុំត្រូវ ។

ដានី ៖ ចុង៧/៨ហ្នឹងយើងដកម៉ោ ដកម៉ោហើយយ៉ាងម៉េចទៀតយើងទៅវិញឬយើងដកម៉ោរហូត?

ខន ៖ ដកម៉ោបើយើងមិនទៅវិញក៏គេបញ្ជាឲ្យទៅ ត្រូវតែទៅដល់ទៅបានឆ្ងាយប៉ុន្មានហ្នឹងយើងអត់ហានថាទេ ។

ដានី ៖ បាទ!កាលហ្នឹងពូនៅវរៈសេនាតូចទៀតឬក៏មានតួនាទីអីឡើងទៀត?

ខន ៖ ខ្ញុំកាលហ្នឹងមានតួនាទីដែរ ។

ដានី ៖ តួនាទីអីដែរកាលហ្នឹង?

ខន ៖ ខ្ញុំឡើងកងធំ ។

ដានី ៖ ឡើងកងធំ?

ខន ៖ បាទ!កងវរយ ។

ដានី ៖ បាទ!កងវរយ អញ្ចឹងកងវរយយើងនៅសមរភូមិពេញម៉ង់អត់នៅក្រោយទេ?

ខន ៖ នៅពេញប្រហែលជា១០០ម៉ែត្រ២០០ម៉ែត្រខ្សែត្រៀមប៉ុណ្ណឹងឯង ។

ដានី ៖ អញ្ចឹង!

ខន ៖ ៣០០ម៉ែត្រ នៅកន្លែង៦០កន្លែងអីហ្នឹង ។

ដានី ៖ ចុះដូចខាងអ្នកដែលដូចថាបញ្ជាពីក្រោយអើ?

ខន ៖ បញ្ជាពីក្រោយកងវរៈហ្នឹងគេបញ្ជា ។

ដានី ៖ កងវរៈទេអញ្ចឹង អញ្ចឹងកងធំគេនៅជាមួយកូនទាហានអីដែរ?

ខន ៖ កងទាហាននៅឆ្ងាយពីកូនទាហានបន្តិចដែលហ្នឹង ប្រហែលជា១០០ម៉ែត្រ២០០ម៉ែត្រកាន់៦០ពីក្រោយហ្នឹង ។

ដានី ៖ បាទ!កាន់៦០?

ខន ៖ ៦០ ចុះកន្លែងភ្លើងស្គុបមាន៦០មានអីហើយភ្លើងត្បាល ។

ដានី ៖ បាទៗ!ចុះយើងវ៉ៃយ៉ាងម៉េចដល់ពេលណាទៅបានយើង យួនវ៉ុកចូលម៉ោចូលដល់ក្រចេះ?

ខន ៖ យួនវាមានប្រៀបខ្លាំងរហូត ដល់ខ្ញុំដល់តែចុងដើមចុង៧/៨ ខ្ញុំត្រូវរបួស ។

ដានី ៖ ចុង៧/៨ត្រូវរបួស?

ខន ៖ បាទ!

ដានី ៖ ត្រូវរបួសនៅណា?

ខន ៖ ខ្ញុំត្រូវរបួសនៅស្មួលហ្នឹង ។

ដានី ៖ នៅស្មួល ត្រូវចំណាទៅ?

ខន ៖ នេះត្រូវធ្លុះធ្លាយពោះហ្នឹង ។

ដានី ៖ ត្រូវពោះហ្នឹង?

ខន ៖ បាទ!ត្រូវពីនេះធ្លាយហ្នឹង(គាត់ចង្អុលទៅលើពោះរបស់គាត់) ។

ដានី ៖ អ្ហូ!ត្រូវគ្រាប់អីហ្នឹង?

ខន ៖ ត្រូវគ្រាប់វេវការ ខ្ញុំឡើងលើដំបូល ។

ដានី ៖ ចុះម៉េចបានឡើងលើដំបូល?

ខន ៖ ឡើងមើលហៅt-oហៅកាំភ្លើងធំវៃដាក់វា ។

ដានី ៖ ដល់ពេល គ្រាប់អីគេវេវការ?

ខន ៖ វេវការត្រូវហើយ ។

ដានី ៖ DKឬវេវការ?

ខន ៖ វេវការ ឥឡូវគ្រាប់នៅនឹងភ្លូវហ្នឹង ។

ដានី ៖ អាវេវការហ្នឹងគ្រាប់ម៉េចទៅ?

ខន ៖ វេវការគ្រាប់ធំៗណាស់ ធំជាងAKវែង ។

ដានី ៖ អាឌូសេ១២?

ខន ៖ មិនមែនទេ អា១២អត់សល់ទេរាប់បាត់ហើយ ខ្ញីជាងAKបន្តិច គេហៅមូសគុង ។

ដានី ៖ ចុះអាហ្នឹងអំបែងឬក៏យ៉ាងម៉េច?

ខន ៖ អាហ្នឹងគ្រាប់ហ្នឹង ។

ដានី ៖ អាហ្នឹងគេវះអីម៉េចបានពូមានស្នាមអីច្រើនម្ល៉េះ?

ខន ៖ អានេះត្រូវ តែត្រូវគេវះដាច់ពោះវៀន តែយើងធ្លាប់ត្រូវគ្រាប់អញ្ចេះហើយតែយើងធ្វើការធូនស្អិតពោះវៀន ស្អិតពោះវៀនគេវះទៀតៗយើងធ្វើការធូនស្អិតពោះវៀនគេវះទៀត ឥឡូវអស់កន្លែងវះហើយ វះ៥ដងហើយ ។

ដានី ៖ វះ៥ដងហើយអញ្ចឹង?

ខន ៖ បាទ!១ដងទៀតអត់ពេលរស់ទេ តែឈើគឺមានតែពេលផាប់ គ្មានពេលណាវះទេឥឡូវ អស់គ្រូមើលទេចប់ហើយ ពោះអស់ហើយគ្មានទេ ពោះរៀននៅតែប៉ុណ្ណេះមានតែគ្រូពះបន្តិចទេ ។

ដានី ៖ អ្ហូ!

ខន ៖ ហើយជើងក៏ពិការទៀតទៅណាបានឥឡូវ ។

ដានី ៖ បាទ!អញ្ចឹងដល់ពេលពូវះទៅវាប៉ះពាល់ដល់ជើងឬក៏ពូត្រូវរបួស?

ខន ៖ អត់ទេ!ជើងត្រូវរបួស កាលវះអត់មានប៉ះពាល់ដល់ជើងទេ ជើងក៏ត្រូវពោះក៏ត្រូវ ។

ដានី ៖ ត្រូវពេលហ្នឹង ត្រូវពេល៧៨ហ្នឹង?

ខន ៖ បាទ!ត្រូវពេលហ្នឹង ។

ដានី ៖ ដល់ពេលពូត្រូវៗចុងឆ្នាំ៧៨ហ្នឹងហើយម៉ោព្យាបាលនៅណា?

ខន ៖ ត្រូវគេដឹកយន្តហោះពីក្រចេះម៉ោភ្នំពេញ ដេកពេទ្យពេញ ។

ដានី ៖ បាទ!ដេកពេទ្យពេញ?

ខន ៖ បាទ!ដេកពេទ្យពេញកំពុងតែរបួសហ្នឹងរត់ពីពេញជិះរទេសភ្លើងម៉ោបាត់ដំបង ។

ដានី ៖ អញ្ចឹងដឹកម៉ោពីពេញម៉ោដេកពេទ្យមួយណា?

ខន ៖ ដេកពេទ្យរុស្សី កន្លែងពេទ្យរុស្សីយើងហ្នឹង ។

ដានី ៖ ពេទ្យ១៧?

ខន ៖ បាទ!កន្លែងពេទ្យហ្នឹង ។

ដានី ៖ បាទ!ដេកពេទ្យហ្នឹងបានរយៈពេលប៉ុន្មានបានម៉ោនៅ?

ខន ៖ ដេកពេទ្យហ្នឹងទាល់តែម៉ារត់ ដល់៦មករាអីហ្នឹង ៥មករាចេញពីពេញហើយ ។

ដានី ៖ បាទ!

ខន ៖ ចេញពីពេញជិះរទេសភ្លើងមកចុះបាត់ដំបង ។

ដានី ៖ បាទ!កាលហ្នឹងពូជារបួសឬនៅ ជម្ងឺរបួស ។

ខន ៖ អេស៍!អត់ទាន់ជាទេនៅ ។

ដានី ៖ អត់ជាទេ?

ខន ៖ បាទ!គាត់ម៉ោតាមផ្លូវមកដេក ដើរពីបាត់ដំបង ដើរជើងឈើពីបាត់ដំបងម៉ោសំឡូត ។

ដានី ៖ បាទ!ដើរថ្មើរជើងម៉ោ?

ខន :	ដើរច្មើរដើង ដើងឈើចុះមនុស្សរាប់រយរាប់ពាន់នាក់ ។

ដានី :	ចុះយើងដើរម៉ោរួចគេឯងដែរ?

ខន :	អេស៎!ថែរគេចេះតែខំគេទៅ សុំអាទេសគេជិះខ្វះយើងដើរខ្វះ ។

ដានី :	ចុះពូម៉េចអត់ទៅស្រុកកណើតជំនាន់ហ្នឹង?

ខន :	ជំនាន់ហ្នឹងដឹងទៅស្រុកកំណើតខ្លាចគេសម្លាប់ចោល ដឹងទៅម៉េចព្រោះគេស្អប់ពួកទ័ព ស្អប់ពួកអី ស្អប់ពួកនិរតី ប៉ុន្តែពួកនិរតីភាគច្រើនវាមិនមែនអ្នកអាក្រក់ទាំងអស់ទេ ។

ដានី :	បាទ!

ខន :	ភាគច្រើនអ្នកដឹកនាំតាមសហករណ៍យើងអត់បានដឹងទេណា៎ ប៉ុនយើងកងទ័ពគ្មានដឹងអី ទេ ។

ដានី :	បាទៗ!

ខន :	ទាំងក្រោយគ្មានបានដឹងទេ ។

ដានី :	ចុះពូដឹងថាគេស្អប់ពួកនិរតីដែរ?

ខន :	ខ្ញុំដឹងថាគេស្អប់ពួកនិរតី ព្រោះគេ ខ្ញុំធ្លាប់នៅនោះបងប្អូនគេនិយាយ ប្រជាជនដើរ ស្រែក ។

ដានី :	ប្រជាជនណា?

ខន :	ប្រជាជនអ្នកបាត់ដំបង ដឹងតែស្អប់ពួកនិរតីហើយអ្នករត់ អូរ!ពូសួរពួកមិរតីអត់ បានទេ ។

ដានី :	ពូដឹងមូលហេតុដែលគេស្អប់ហ្នឹង?

ខន :	ខ្ញុំធ្លាប់ដឹងមូលហេតុដែរ ដូចថាអ្នកនិរតីភាគច្រើនម៉ោសម្លាប់បងប្អូនអ្នកបាត់ដំបងច្រើន បង្អត់បាយ បង្អត់ទឹកយើងម៉ោតាមសហករណ៍ហ្នឹងភាគច្រើនអ្នកនិរតីគ្រប់គ្រង គ្រប់ តំបន់បាត់ដំបងទាំងអស់ ។

ដានី :	បាទៗ!អញ្ចឹងកាលពូទៅសមរភូមិ ទៅធ្វើអីដូចថាខាងអគ្គសេនាធិការខាងតាសុន សេន អីគាត់ដែលចុះទៅអី?

ខន :	អត់ដឹងទេអូន រឿងគេធំៗ អត់ដឹងគេទេព្រោះយើងកូនទាហានតូចតាចមានបានដឹងអី ។

ដានី :	ចុះពេលដេកពេទ្យអីគាត់មានដែលទៅចូលសួរសុខទុក្ខអីទេ?

ខន :	អត់ដែលឃើញអ្នកណាទៅសួរសុខទុក្ខទេ ។

ដានី :	អគ្គសេនាធិការ អគ្គសេនាធិការរងអី?

ខន :	អត់ទេ ។

ដានី : កាលហ្នឹងអគ្គសេនាធិការ សុន សេន អញ្ចឹងតាសុន សេន?

ខន : អេស៎!អត់ដឹងទេ រឿងធំៗអញ្ចឹងអត់បានដឹងទេ ។

ដានី : បាទ!អត់ដឹងទេអគ្គសេនាធិការអី?

ខន : អត់ យើងតូចតាច ។

ដានី : បាទ!ពេលរត់ម៉ោពួកគាត់មានរត់ម៉ោជាមួយដែរឬអត់?

ខន : ទេ!រត់ម៉ោយើងដើររហូត មិនដឹងគេរត់តាមផ្លូវណាបើយើងអត់ដឹង ។

ដានី : អត់ដឹងទេ?

ខន : បាទ!អត់ដឹង ។

ដានី : ប៉ុន្តែដល់ពេលពូរត់ម៉ោបានពូដឹងថាគេ ពួកខាងបាត់ដំបងអីហ្នឹងគេស្អប់ពួកនិរតី?

ខន : បាទគេស្អប់ ។

ដានី : ចុះពូម៉េចដឹងថា បើពូអត់ប្រាប់គេថានិរតីម៉េចគេដឹង?

ខន : អីមិនដឹង បើគេស្តាប់យើងនិយាយ ។

ដានី : អ្ហូ!ស្តាប់និយាយ?

ខន : សំដីសំដៅខុសគ្នាអ្នកបាត់ដំបង គ្រាន់តែយើងនិយាយក៏គេដឹងថាយើងអ្នកនិរតីដែរ ។

ដានី : ប៉ុន្តែយើងអាចបកស្រាយប្រាប់គេថា យើងកងទ័ពយើងអី?

ខន : យើងអាចប្រាប់គេបាន យើងថាយើងអត់មានដឹងអីទេ យើងធ្លាប់នៅៗហ្នឹង ។

ដានី : មានដែលមានគេសួរពូអីដែរអញ្ចឹងដែរឬអត់?

ខន : មានគេសួរខ្ញុំច្រើនដែរ ។

ដានី : គេសួរប៉ុន្តែគេប្រាប់ថាគេស្អប់អញ្ចឹង?

ខន : ភាគច្រើនគេស្អប់មេដឹកនាំពួកនិរតីមកធ្វើបាបគេ ។

ដានី : គេសួរហ្នឹងគេប្រុងធ្វើបាបពូឬក៏យ៉ាងម៉េច?

ខន : ភាគច្រើនគេរកធ្វើបាបយើងដែរ ។

ដានី : ប៉ុន្តែគេមានធ្វើបាបពូដែរឬអត់ទេ?

ខន : ខ្ញុំគេអត់មានធ្វើបាបទេ គេរត់សំណាងរហូតខ្ញុំ សំណាងបានគេជួយលាក់ ខ្ញុំមានឪពុកធម៌ម្តាយធម៌រហូត ។

ដានី : ឪពុកធម៌ម្តាយធម៌នៅណា?

ខន ៖ នៅសំឡូតនោះ ខ្ញុំរត់ម៉ោខ្ញុំនៅសំឡូតផ្ទះសហករណ៍គេប៉ុន្មានឆ្នាំនោះ ។

ដានី ៖ អ្ហូ!រយៈពេលប៉ុន្មានទៅ?

ខន ៖ ហ៊ឺ!ច្រើនដែរហ្នឹងរហូតដល់បានប្រពន្ធនេះ ។

ដានី ៖ អូរ!ពូរៀបការឆ្នាំណា?

ខន ៖ ខ្ញុំរៀបការកំពុងរត់៧៩ ។

ដានី ៖ ៧៩?

ខន ៖ បាទ!

ដានី ៖ ពូរៀបការតាំងពីឆ្នាំ៧៩នោះ?

ខន ៖ បាទ!បានឪពុកម្ដាយធម៌នៅបវេលនេះឥឡូវគាត់ស្លាប់អស់ហើយ ។

ដានី ៖ អ្ហូ!ពូការនៅណា?

ខន ៖ អេស៎!សែនអស់តែមាន់១គូរ ។

ដានី ៖ សែននៅណា?

ខន ៖ នៅបវេលហ្នឹង ។

ដានី ៖ នៅបវេល អញ្ចឹងពូ?

ខន ៖ កំពុងរត់ហ្នឹង ។

ដានី ៖ កំពុងរត់មកដល់បវេលអញ្ចឹងរៀបទាំងពិការម៉ង?

ខន ៖ បាទ!ការទាំងពិការជើងឈើហ្នឹង ។

ដានី ៖ អ្ហូ!

ខន ៖ ខ្ញុំថាក្រៅពីគាត់ក៏គេមិនយកខ្ញុំដែរ បើខ្ញុំជើងពិការទៅធ្វើអីកើត បានជាគ្នាទៅ ក្រៅពីគាត់ក៏គេមិនយកខ្ញុំដែរ ។

ដានី ៖ ចុះមីងម៉េចបានស្រឡាញ់គាត់កាលហ្នឹងគាត់ពិការអីផង?

ប្រពន្ធ ៖ គាត់សើច ។

ខន ៖ ជើរជើងឈើ ។

ដានី ៖ បាទ!មីងកាលហ្នឹងម៉េចគិតថាស្រឡាញ់គាត់ រៀបការជាមួយគាត់?

ប្រពន្ធ ៖ គិតថាបេះអាណិតហ្នឹង ។

ដានី ៖ អញ្ចឹងពេលមីងការហើយ រត់ម៉ោតមកទៀត?

ខន : ការហើយ គោលបំណងខ្ញុំ ខ្ញុំអត់ចង់នៅស្រុកខ្មែរទេ ខ្ញុំថាលំបាកណាស់ ។

ដានី : បាទ!

ខន : ចង់ទៅអាមេរិចឯណាណីនោះ ។

ដានី : បាទ!

ខន : ខ្ញុំម៉ោពីហ្នឹងរត់ការអីហើយ ខ្ញុំនាំគ្នា ពួកគេខាងលិច តំបន់ខាងលិចនេះមានកាកបាទក្រហមជួយ ។

ដានី : បាទ!

ខន : កាកបាទក្រហមជួយមកដល់ព្រៃខ្ពស់ស្វាយសាមនយើងនេះ ព្រៃខ្ពស់ស្វាយសាមនៗ ស្រុកមង្គលបុរីឬស្រុកអីទេ អូស៎! ព្រៃខ្ពស់ស្រុកបវេលៗហ្នឹងជួបទាហានខ្មែរក្រហមហ្នឹងទាហាន ។

ដានី : បាទ!

ខន : ទាហានខ្មែរក្រហមគេឃើញយើងពិការអញ្ចឹងគេអាណិត ។

ដានី : បាទ!

ខន : គេសុំអាទេសប្រជាជនមកយកអង្ករនេះគេឲ្យយើងជិះម៉ោ ជិះម៉ោដល់កន្លែងកាកបាទក្រហមគេហ្នឹង ។

ដានី : បាទ!

ខន : ដល់កាកបាទក្រហមគេហ្នឹងបានសុំគេបានដេកពេទ្យព្យាបាលរបួស ព្យាបាលទៅហើយបានទៅថាវដាងទៀតខ្ញុំ ។

ដានី : បាទ!

ខន : ដល់ថាវដាងហ្នឹងប្រុងបានទៅអាមេរិចហើយ គេហៅទៅ ប៉ុនទាស់ប្ដីប្រពន្ធ ប្រពន្ធខ្ញុំគេអត់ឲ្យទៅ គេឲ្យខ្ញុំទៅតែឯងបារាំង ប៉ុនប្រពន្ធគេអត់ឲ្យទៅ ។

ដានី : ទៅបារាំង?

ខន : បារាំងវាឲ្យខ្ញុំទៅ ។

ដានី : ទៅអាមេរិចឬទៅបារាំង?

ខន : បារាំងវាឲ្យខ្ញុំជិះឡានទៅថាវដាងនៅប្រទេសថៃ ។

ដានី : អ្ហូ!

ខន ៖ តែខ្មែរយើងគេអត់ឲ្យប្រពន្ធខ្ញុំទៅ ។

ដានី ៖ ហេតុអីអញ្ជឹង?

ខន ៖ គេថាយើងអត់ម៉ោវិញ ។

ប្រពន្ធ ៖ គេកំពុងប្រមូលកម្លាំង ។

ខន ៖ កុំអីអត់ម៉ោវិញទេ ។

ដានី ៖ ខ្មែរយើងអត់ឲ្យទៅម៉េច បានន័យថា?

ខន ៖ គេឲ្យយើងទៅព្យាបាលស្រុកគេនោះ ស្រុកថៃនោះថាវដាង ។

ដានី ៖ ប៉ុន្តែកងទ័ពខាងខ្មែរក្រហម?

ខន ៖ អត់ទេ ខាងសុខាភិបាលខាងពេទ្យខ្មែរក្រហមគេហ្នឹង គេមិនឲ្យប្រពន្ធខ្ញុំទៅទេ ។

ដានី ៖ អ្ហូ!

ខន ៖ គេខ្លាចពីរនាក់ហ្នឹងអត់ម៉ោវិញ ។

ដានី ៖ អ្ហូ!

ខន ៖ បើទៅពីរនាក់អត់ម៉ោវិញមែន គោលបំណងអត់ម៉ោវិញទេ ។

ដានី ៖ អ្ហូ!

ខន ៖ ប៉ុនគេឲ្យខ្ញុំទៅតែឯង ។

ដានី ៖ អ្ហូ!បាទ ហើយម៉េចទៀតទៅ?

ខន ៖ ប៉ុនទៅតែឯងគេធ្វើគេស្គួសម្ភាសន៍ខ្ញុំចង់ទៅដែរ តែអាណិតដូចថាធ្លាប់យើងពិការកំសត់កំរគាត់ធ្លាប់ចិញ្ចឹមយើង អូសដៃយើង ដាំបាយទឹកឲ្យយើង យើងទៅចោលគាត់វាអត់កើត ។

ដានី ៖ អ្ហូ!

ខន ៖ ដូចថាមានការអាណិតអាសូរ សុខចិត្តម៉ោវិញលំបាកៗចុះ ដល់ម៉ោវិញកម្សរហូតដល់សព្វថ្ងៃហ្នឹង ។

ដានី ៖ បាទ!ចុះពូមិនប្រាប់គាត់ថាពូទៅមុនសិនហើយពូចាំម៉ោវិញ?

ខន ៖ ចុះជំនាន់ហ្នឹងមានទូរស្ព័ទាក់ទងគ្នា ជំនាន់ហ្នឹងអត់មានទេអូន មានតែកាកបាទក្រហមមានអី ។

ដានី ៖ យើងអាចថា កាលហ្នឹងបើយើងនេះ អ្ហូ!មើងគាត់ចាំសិនទៅ ពូទៅសិនទៅមុនហើយ ទៅនៅមានកន្លែងមានអីត្រឹមត្រូវហើយបានយើងធានាយកទៅ?

ប្រពន្ធ ៖ គេមិនឲ្យទៅទេៗ គេឲ្យតែអ្នកជំងឺទៅ ។

ដានី ៖ គេឲ្យតែអ្នកជំងឺទៅ?

ខន ៖ គេឲ្យតែអ្នកជំងឺទៅ ។

ដានី ៖ អញ្ចឹងពូបានទៅដល់ហ្នឹង បានទៅព្យាបាលដែរឬអត់ទេ?

ខន ៖ បាទ!បានទៅព្យាបាលនៅស្រុកគេហ្នឹង នៅស្រុកថៃថាវដាង ។

ដានី ៖ បាទ!ព្យាបាលបានរយៈពេលប៉ុន្មានទៅ បានយើងត្រឡប់មកវិញ?

ខន ៖ អេស៎!យូរបាន២-៣ខែមិនដឹងល្មម ម៉ាជាស្រួលបួលបានម៉ោវិញ ។

ដានី ៖ បាទ!ជាស្រួលបួលហើយបានម៉ោវិញ?

ខន ៖ បាទ!

ដានី ៖ ម៉ោវិញយ៉ាងម៉េចទៀតទៅ?

ខន ៖ ម៉ោវិញជួបជុំគ្រួសារនៅធម្មតាអញ្ចឹងទៅ ។

ដានី ៖ នៅណា?

ប្រពន្ធ ៖ នៅគេនៅឯងរហូតមកដល់ឥឡូវ ។

ខន ៖ នៅនេះនៅគីឡូ១២នេះ ។

ដានី ៖ ក្នុងដីថៃ?

ខន ៖ គីឡូ១២ គីឡូ១៣ក្នុងសំពៅលូនយើងរាល់ថ្ងៃនេះ ។

ដានី ៖ អ្ហូ!សំពៅលូន?

ខន ៖ បាទ!

ដានី ៖ នៅហ្នឹង នៅរហូតទាល់តែយ៉ាងម៉េច?

ខន ៖ នៅហ្នឹងគេឃើញយើងពិការអញ្ចឹងគេឲ្យយើងចាំឃ្លាំងឲ្យគេ ។

ដានី ៖ នៅចាំឃ្លាំង?

ខន ៖ បាទ!ឃ្លាំងអង្ករ ឃ្លាំងមីអញ្ចឹងទៅ ។

ដានី ៖ ឃ្លាំងមីសម្រាប់បើឲ្យកងទ័ព?

ខន ៖ បាទ!

ដានី : កាលហ្នឹងខាងកងទ័ព ខាងកងពលខាងណាទៅ?

ខន : កងពលជំនាន់ហ្នឹងគេហៅកងពលប៉ុន្មានទេ ។

ដានី : ពីណាគេប្រធានកងពល?

ខន : ជំនាន់ហ្នឹងតានាយ កន នោះធំ ។

ដានី : តាណា?

ខន : តាកន នៅ៣២រាល់ថ្ងៃហ្នឹង ។

ដានី : តានាយ កន?

ខន : បាទ!

ដានី : គាត់ធំ?

ខន : គាត់មាឌធំជាងគេ ខ្ញុំនៅជាមួយតារុមនេះកន្លែងកងពលតារុមនេះ តារុមសព្វថ្ងៃនេះ ។

ដានី : តារុម គាត់ធ្វើអីគេ?

ខន : តារុម នៅហ្នឹងគាត់វរៈសេនាធំដែរមិនដឹង ដូចវរៈសេនាធំ ។

ដានី : បាទ!វរៈសេនាធំដូចតា ប៉ៃ ដែរ?

ខន : មែនទេ គាត់ធមជាងតា ប៉ៃ ។

ដានី : ធំជាងតាប៉ៃ?

ខន : បាទ!

ដានី : បាទ!អញ្ចឹងពូនៅឃ្លាំងហ្នឹងរហូត?

ខន : នៅចាំឃ្លាំងហ្នឹងរហូត ។

ដានី : ចុះដល់ពេលយួនវៃចូលឆ្នាំ៧៩អី យួនដាក់កាំភ្លើងធំដាក់អីមកលើភ្នំនេះពូទៅណាវិញទៅ?

ខន : នេះនៅលិចនេះ លិចភ្នំនេះ ។

ដានី : ចូលដីថៃវិញ?

ខន : បាទ!ដីថៃនេះនៅក្បែរនេះ ។

ដានី : ក្បែរហ្នឹងដែរ?

ខន : បាទ!ក្បែរនេះប្រហែលជា២គីឡូដល់ហើយ ។

ដានី : យួនមានវៃផ្លោងចូលឬអត់?

ខន ៖ អេស៎!ផ្ទៅងចូលរត់តែរហូតហ្នឹង យប់ឡើងក៏រត់ថ្ងៃក៏រត់ដែរ ភាគដែលនៅរាល់ថ្ងៃហ្នឹងបានតិចណាស់ ព្រលឹមឡើងដាំបាយហូប ហូបហើយចង់ឆ្នាំងហើយ ត្រៀមរត់វ៉ៃណាចោលហ្នឹង ទៅនោះទៀតហើយគេវ៉ៃទៀតទៅ រត់ដល់នោះគេវ៉ៃនោះ កាកបាទគេតាមជួយ ។

ដានី ៖ ចុះកាលហ្នឹងយើងមានរបបហូបចុកគ្រប់គ្រាន់ដែរ?

ខន ៖ អត់អេស៎!ហូបចុកអត់ខ្វះទេ ព្រោះកាកបាទគេជួយ មានអង្ករ មានម្ហូបមានស្ករមានអីមានទាំងអស់ ។

ដានី ៖ អញ្ចឹងស្រួលទេ អត់ពិបាក?

ខន ៖ អត់ពិបាកទេអូន ។

ដានី ៖ ពិបាកតែរត់?

ខន ៖ ពិបាកតែរត់ ពេទ្យក៏អតលពិបាកដែរ ថ្នាំគឺមានតែយើងបោះចោលគេឲ្យយើង ។

ដានី ៖ បាទ!នៅដីថៃបានយូរដែរអញ្ចឹង?

ខន ៖ អេស៎!នៅដីថៃបានយូរៗ រហូតដល់ឆ្នាំ៩០ប៉ុន្មានទេ កិច្ចចរចាព្រមព្រៀងបារីសបានគេបញ្ជូនមកនៅដីខ្មែរវិញ ។

ដានី ៖ បាទ!កាលហ្នឹងយួនចេញទៅវិញអស់ហើយ?

ខន ៖ យួនចេញទៅវិញអស់ហើយ ។

ដានី ៖ យើងវ៉ៃបានឬក៏យួនចេញទៅខ្លួនឯង?

ខន ៖ អេស៎!បងប្អូនភាគច្រើនគេវ៉ៃ ។

ដានី ៖ គេវ៉ៃ?

ខន ៖ បាទ!គេកង់ទ័ពគេវ៉ៃយើងទេ គេត្រូវវ៉ូវគ្នាដើរបណ្ដើរទៅ ។

ដានី ៖ គេត្រូវវ៉ូវគ្នាខាងក្នុងក៏ត្រូវទៅយើងវាងធូរយើងវ៉ៃយកម៉ោបាន?

ខន ៖ បាទ!ប្រពន្ធឆ្លើយ (ដូចថាយើងផ្ដាច់ខ្លួនចូលគេអីអញ្ចឹងទៅណា៎) ។

ដានី ៖ បាទៗ!កាលហ្នឹងពូមានតួនាទីអីឬអត់ កាលពូនៅឃ្លាំងអីហ្នឹងយើងមានឋានៈមានអីដែរឬអត់?

ខន ៖ ខ្ញុំធ្វើភស្តុភាជំនាន់ហ្នឹង ។

ដានី ៖ ធ្វើខាងភស្តុភារបស់អី?

ខន ៖	ភស្តុភារបស់វរៈសេនាធំ ។

ដានី ៖	ភស្តុភារបស់វរៈសេនាធំ ប្រធានភស្តុភាវរៈសេនាធំ?

ខន ៖	កូនគេទេ មិនមែនប្រធាន ។

ដានី ៖	កូនគេទេ?

ខន ៖	បាទ!

ដានី ៖	យើងនៅតែខាងក្រោយទេណ៎?

ខន ៖	នៅតែខាងក្រោយ ។

ដានី ៖	បាទ!អញ្ចឹងដល់ពេលចូលម៉ោវិញ ពេលដែលយើងវិបានចូលមកវិញត្រូវគ្នាកិច្ចព្រមព្រៀងទីក្រុងបារីសហ្នឹងហើយយ៉ាងម៉េចទៀតទៅ?

ខន ៖	កិច្ចព្រមព្រៀមទីក្រុងបារីសអីហើយមិនវិគ្នាមួយសារទៀត?

ដានី ៖	វិពេលណាទៀត?

ខន ៖	ចុះជំនាន់ចរចាមិនត្រូវគ្នា ខ្លះនៅក្រៅច្បាប់ខ្លះនៅក្នុងច្បាប់មិនវិម៉ាសារទៀត ។

ដានី ៖	អ្ហូ!ឆ្នាំ៩៦ហ្នឹង?

ខន ៖	ដល់៩៦ហ្នឹងបានត្រូវគ្នាមែនទែន ។

ដានី ៖	បាទ!ជំនាន់ខាងប៉ៃលិន ខាងម៉ាឡៃ?

ខន ៖	បាទ!អាហ្នឹងបានត្រូវគ្នាមែនទែន ។

ដានី ៖	បាទ!

ខន ៖	អាហ្នឹងកាលម៉ាឡៃ កាលប៉ៃលិនត្រូវគ្នាហ្នឹង អាហ្នឹងដើរអត់រួចទេ នៅវះពោះមួយសារទៀតកាលហ្នឹង ។

ដានី ៖	វះពោះមួយសារទៀត?

ខន ៖	ចុកពោះខ្លាំងវះពោះ១ដងទៀង ។

ដានី ៖	នៅណា ទៅវះនៅណា?

ខន ៖	វះនៅពេទ្យកំរៀងនោះ ។

ដានី ៖	អ្ហូ!ពេទ្យកំរៀង ។

ខន : កាលវះហ្នឹងដើរអត់រូប ពួកប៉ៃលិនម៉ោហ្នឹងដើរអត់រូបទេ គេសែងរត់ ទៅដល់ភ្នំលិច នោះពួកប៉ៃលិននៅតាមនេះ ជំនាន់ហ្នឹងមើលគេអត់ឃើញទេ វះថ្នាំសន្ធប់ច្រើន មើលគេអត់ឃើញទេ ។

ដានី : ស្រវាំងភ្នែក?

ខន : ស្រវាំងភ្នែក វះច្រើនខូចភ្នែកអស់ហើយ ។

ដានី : បាទ!ចុះម៉េចដែរឮថា ដល់ពេលក្រោយម៉ោពូដូចថាកាលហ្នឹងយើងម៉ោនៅ យើងមានផ្ទះយើងចាប់ផ្ទះនៅជាឯកជន ឬយើងនៅជារួមដដែល ព្រោះក្រោយពេលដែលយើងវិញ?

ខន : ម៉ោវិញនៅជាឯកជនអូន យើងកាប់ព្រៃនៅខ្លួនឯង រាវមីនរាវអីរាវមីនកាប់ព្រៃកាប់អីទៅ អ្នកកាប់បានច្រើនយកច្រើនអ្នកកាប់បានតិចយកតិចទៅ ។

ដានី : បាទ!អញ្ចឹងកាលហ្នឹងយើងចាប់ផ្តើមនៅខ្លួនឯង?

ខន : នៅខ្លួនឯងជីវភាពថ្មី អាហ្នឹងរកខ្លួនឯងហើយគ្មានអ្នកណាគេជួយទេ ។

ដានី : បាទៗ!

ខន : កាកបាទក៏គេផ្តាច់ជំនួយយើងដែរ គេលែងជួយយើងហើយ ។

ដានី : បាទ!ចុះដូចតាតា ដូចថាគាត់អត់ត្រូវគ្នា ឈ្លោះគ្នាម៉េចទៅ?

ខន : អេស៎!រឿងថ្នាក់ធំៗខ្ញុំអត់សូវដឹងដែរអូន មិនដឹងយ៉ាងម៉េចគេដែរ យើងក្រោមៗ ។

ដានី : បាទ!ដល់ក្រោយម៉ោឮថា តាសុន សេន គាត់ប្រមូលរបស់របរមកដាក់ដាក់អីយ៉ាងម៉េចៗទៅ?

ខន : អេស៎!កាលជំនាន់ខ្លាំងវាខ្លាំងដែរជំនាន់ហ្នឹង ជំនាន់ សុន សេនខ្លាំងណាស់គេកុំតែផ្តាច់ខ្លួនទាន់ប្រហែលជាគ្រោះថ្នាក់ច្រើន ។

ដានី : គ្រោះថ្នាក់ច្រើនម៉េច?

ខន : ប្រហែលជាបងប្អូនស្លាប់ច្រើនកុំតែផ្តាច់ខ្លួនទាន់ ព្រោះសុន សេនគាត់ធ្វើបាបណាស់ ។

ដានី : គាត់ធ្វើបាប?

ខន : បាទ! រកស៊ីអត់បាន សូម្បីតែយកគោជីកឈើ ក៏ដាក់គុកទាំងគោដែរមិនចាំបាច់តែមនុស្សទេ ។

ដានី : អញ្ចឹង?

ខន ៖ អេស៎! សុន សេនខ្លាំងណាស់មិនធម្មតាទេ ។

ដានី ៖ គាត់កាចណាស់?

ខន ៖ កាចណាស់ ។

ដានី ៖ ចុះតា កន បងប្អូនគាត់ដែរ?

ខន ៖ តាកន អត់អីសម័យតាកន ដូចអត់មានអីដែរ ។

ដានី ៖ អត់អីទេ?

ខន ៖ បាទ!

ដានី ៖ ខ្លាំងតែ សុន សេន ប្រជាជនអត់ចូលចិត្តគាត់ទេអញ្ចឹង?

ខន ៖ ប្រជាជនភាគច្រើនបើនៅសុន សេន យ៉ាប់ណាស់ ។

ដានី ៖ ដល់ពេល៩៦ យើងផ្តាច់?

ខន ៖ អូស៎!ផ្តាច់ហើយស្រួលណាស់ ។

ដានី ៖ ផ្តាច់ខ្លួនម៉ោស្រួល?

ខន ៖ ស្រួលរហូត ។

ដានី ៖ ហើយចុះពូបានទៅលេងផ្ទះវិញឆ្នាំណាដែរ?

ខន ៖ អេស៎!បានទៅលេងផ្ទះមិនដឹងជាឆ្នាំណាទេអូន ផ្តាច់ខ្លួនហើយស្រួលបួល ។

ដានី ៖ ទៅលេងផ្ទះបានច្រើនដងដែរ?

ខន ៖ ទៅលេងផ្ទះបាន២-៣ដងហើយអូន ទៅមិនកើតម៉ែឪយំហ្នឹង ។

ដានី ៖ អឹម!ពូកែយំពេក?

ខន ៖ អត់ទេ!គាត់ថា កាលទៅម៉ោផ្ទះវាដៃជើងវាល្អពេក ដល់ទៅមានជើង២ ជើង៣ ក្រង៉ែងក្រង៉ាងពិបាកមើលណាស់ ។

ដានី ៖ បាទ!

ខន ៖ គាត់យំថា មិនគួរណាអញ្ចឹងទេម៉ោដៃស្អាត ជើងស្អាតដល់ទៅវិញអស់ពោះអស់ជើង ។

ដានី ៖ គាត់ហ្នឹង?

ខន ៖ ឪពុកគាត់ វាអត់មានបានប្រយោជន៍អីការពិតទោសម្ចាប់តែគ្នាឯងឥតប្រយោជន៍ ។

ដានី ៖ បាទ!គិតថាវាអត់ប្រយោជន៍?

ខន ៖ អត់ប្រយោជន៍ ។

ដានី :	យើងវៃតែខ្មែរគ្នាឯងទេ?

ខន :	វៃតែខ្មែរគ្នាឯង បើដឹងអញ្ចឹងគ្មានអ្នកណាទៅខំធ្វើអីទេ ឥឡូវចង់ធ្វើទាហានទៀតទេ អត់ទេ!ឈប់ហើយ ។

ដានី :	ឈប់ម៉ង់?

ខន :	មិនចង់ធ្វើទេសង្គ្រាម ។

ដានី :	ទោះជាសង្គ្រាម ទោះជាគេហៅទៅ?

ខន :	យ៉ាងម៉េចក៏ដោយក៏អត់ចង់ដែរ ។

ដានី :	បាទ!

ខន :	កុំតែបានសម្តេចទេ ក្រៅពីហ៊ុន សែនក៏មិនបានប៉ុណ្ណឹងដែរ ។

ដានី :	អញ្ចឹង! សម្តេចយ៉ាងម៉េចដែរ?

ខន :	អេស៎!សម្តេច ហ៊ុន សែន គាត់ល្អណាស់ ។

ដានី :	គាត់យ៉ាងម៉េច គាត់ល្អយ៉ាងម៉េច?

ខន :	គឺថាទស្សនៈនយោបាយគាត់ដឹកនាំគឺល្អអញ្ចឹងម៉ង មិនមែនអ្នកចាញ់ មិនមែនអ្នក ឈ្នះ ។

ដានី :	បាទ!ឲ្យយើងរស់ទាំងអស់គ្នា?

ខន :	ឲ្យយើងរស់ទាំងអស់គ្នា នៅណានៅហ្នឹងទៅបងប្អូនរកអីបានហូបៗទៅធម្មតា ប្រកបរបររកស៊ី ។

ដានី :	ប៉ុន្តែពូយល់ឃើញយ៉ាងម៉េចដែរដូចថា កាលពីមុនសាមាហរណកម្មយើងរស់យើងមានរបរយើងមានអីអញ្ចឹងយើងមិនខ្វល់ ដល់ពេលឥលូវយើងរស់ យើងត្រូវរកស៊ីខ្លួនឯងចិញ្ចឹមខ្លួនឯងយ៉ាងម៉េចដែរ ខុសគ្នាអញ្ចឹង ពូយល់ឃើញថាយ៉ាងម៉េចមួយណាស្រួលជាង?

ខន :	អេស៎!អាហ្នឹងវារកស៊ីខ្លួនឯងអញ្ចឹងវាមានអីវាស្រួល បាទ!របស់គេជួយវាមិនដូចយើងរកខ្លួនឯងទេ ។

ដានី :	អញ្ចឹង?

ខន :	បាទ!គេថា យើងអត់ជួយខ្លួនឯងផង ទេវតាណាគេជួយយើង ដល់យើងខំជួយខ្លួន ឯង ។

ដានី :	បាទ!

ខន :	ប៉ុនទេវតាគេជួយយើង ។

ដានី ៖ បាទ!ខ្ញុំជួបពូមីងម៉ាចំនួនតូចគាត់មានប្រសាស៍ថា កាលពីមុនស្រួល គេមានរបបគេបើកឲ្យយើង យើងមិនចាំបាច់ខ្វល់ មិនបាច់រកស៊ីក៏យើងមានហូបមានចុក ដល់ឥឡូវនេះបើយើងមិនប្រឹងប្រែងរកស៊ីគាត់ថាអត់មានអីហូបមានអី ពិបាក ។

ខន ៖ បើយើងមិនប្រឹងប្រែងយើងអត់ហើយ គ្មានអ្នកណាគេជួយយើង បើងយើងមិនជួយខ្លួនឯងគ្មានអ្នកណាគេជួយយើង បើយើងមិនជួយខ្លួនឯង អត់ធ្វើគ្មានអ្នលណាគេឲ្យយើង ។

ដានី ៖ បាទ!

ខន ៖ ដល់យើងខំដែលបានគេជួយយើងបាន សូម្បីតែរកឲ្យគេក៏ដោយ បើសិនជាយើងខ្ជិលគ្មានអ្នកណាគេឲ្យយើងស៊ីទេ ។

ដានី ៖ បាទ!ចុះពូ ពូអត់ចង់ទៅនៅស្រុកកំណើតវិញទេ?

ខន ៖ ហ៊ឺ!ទៅនៅស្រុកកំណើតមិនបានអីទេអូន ទៅនៅដៃទទេ ។

ដានី ៖ អត់មានដីអត់មានធ្លីទេ?

ខន ៖ អត់មានដីអត់មានធ្លី យើងមានអីគេ បើគេចែកអីអស់ហើយ ជំនាន់យើងនេះយើងមានអីទៀត ម៉ែឪយើងសុទ្ធតែអ្នកក្រ ។

ដានី ៖ ចុះបងប្អូនពូគាត់នៅស្រុកកំណើតទាំងអស់ឬក៏ម៉ោនេះ?

ខន ៖ គេនៅស្រុកកំណើតទាំងអស់ ខ្ញុំនៅនេះក្បាលមួយតែឯងហ្នឹង ។

ដានី ៖ អ៊ូ!បាទចុះពេល ដូចថាពូនៅនេះយូរ ហើយស្រុកកំណើតពូគិតថារស់នៅណាវាស្រួលជាង?

ខន ៖ ខ្ញុំគិតថាស្រុកនេះវាស្រួលជាង ។

ដានី ៖ ស្រួលជាង?

ខន ៖ បាទ!

ដានី ៖ យើងមានដីធ្លី?

ខន ៖ មានដីធ្លីតិចតួចដែរ រកស៊ីអីក៏វាមិនសូវពិបាកវាស្រួលស្រណុករក ។

ដានី ៖ ប៉ុន្តែយើង ចុះពូដូចថាទៅលេងផ្ទះអីទៅយូរៗទេ?

ខន ៖ អត់ទេ!អស់យូរហើយ៨ថ្ងៃ ។

ដានី ៖ ម៉េចនឹកខាងនេះទេ?

ខន ៖ ទេវាដូចលំបាកណាស់ទៅស្រុកវាលំបាក ។

ដានី ៖ លំបាកម៉េចទៅ?

ខន ៖ វានោះវាលំបាក ដូចថាយើងទៅផ្ទះគេវាលំបាកបងប្អូន ។

ដានី ៖ បាទ!ដូចថាបងប្អូនមែនវា?

ខន ៖ វាលំបាកដែរ ។

ដានី ៖ ចុះញាតិមិត្តបងប្អូនដែល មិត្តភក្រ្កពូកាលពីក្មេងៗទៅនៅស្គាល់គ្នារាប់អានជិតស្និត?

ខន ៖ អត់ទេ!បាត់អស់នៅក្នុងភូមិខ្ញុំហ្នឹងឃើញនៅសល់តែ២នាក់ ម៉ាស្រុករខ្ញុំ ។

ដានី ៖ ឃើញតែ២នាក់?

ខន ៖ បាទ!ឃើញតែ២នាក់ អត់មានជួបបាត់អស់ហើយ ប៉ុនមិនដឹងគេនៅណាខ្លះអត់ដឹង ឬក៏ស្លាប់ឬក៏រស់អត់ដឹង ។

ដានី ៖ បាទៗ!ចុះបងប្អូនពូដែលមកលេងនេះដែរឬអត់?

ខន ៖ ដែលម៉ោដែល ។

ដានី ៖ ម៉ោដែល?

ខន ៖ បាទ!

ដានី ៖ ចុះពូធ្លាប់ទៅលេងស្រុកខាងមីងទេ?

ខន ៖ ទៅស្រុកគាត់ជិត ។

ដានី ៖ ចុះពូ ពូសំនួរចុងក្រោយមកដល់សព្វថ្ងៃនេះខាងរាជរដ្ឋាភិបាលហើយនឹងខាងអង្គការសហប្រជាជាតិបានបង្កើតតុលាការមួយដើម្បីជំនុំជំរះទោស មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមហើយនឹងជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះឧក្រិដកម្មធ្ងន់ធ្ងរកាលពីសម័យកម្ពុជាប្រជាធិបតេយ្យពី៧៥ដល់៧៩ ដូចជា កាំង ហ្កេវអាវហៅឌុច អតីតប្រធានមន្ទីរសន្តិសុខ ស២១ ហៅគុកទួលស្លែង ត្រូវបានតុលាការគេជំនុំជំរះទោសគាត់រួចហើយ ហើយពេលខាងមុខឆាប់ៗនេះ គេនឹងជំនុំជំនះមេដឹកនាំជាន់ខ្ពស់៤រូបទៀតដូចជា នួន ជា ខៀវ សំផន អៀង សារី ហើយនឹងប្រពន្ធរបស់គាត់ ។

ខន ៖ បាទ!

ដានី ៖ បាទ!អញ្ចឹងចំពោះទស្សនះរបស់ពូ ពូយល់ឃើញយ៉ាងម៉េចដែលចំពោះតុលាការដែលគេបង្កើតឡើងកាត់ទោសហ្នឹងត្រូមត្រូវដែរឬមិនត្រូវទេ តុលាការហ្នឹង?

ខន : តាមការយល់ឃើញរបស់ខ្ញុំ ខ្ញុំគិតថាតុលាការហ្នឹងជាតុលាការត្រឹមត្រូវ កាត់ទោសអ្នកដែលមានកំហុស ។

ដានី : កំហុសយ៉ាងម៉េច?

ខន : កំហុសអ្នកធ្វើខុសជិតនាន់ពាឆ្នាំហ្នឹង ធ្វើឲ្យប្រជាជនអត់បាយ បែកបាក់គ្រួសារ ស្លាប់ដោយសារសង្គ្រាម ។

ដានី : បាទ!ពូថាត្រឹមត្រូវនោះ?

ខន : ខ្ញុំថាត្រឹមត្រូវ បើមិនកាត់ទោសអញ្ចឹង គេថាប្រទេសយើងអត់មានច្បាប់មានទម្លាប់អីយើងធ្វើបានស្រេចតែចិត្ត អ្នកដែលមានកំហុសអ្នកដែលមានទោសរួចខ្លួន ។

ដានី : បាទៗ!

ខន : ការកាត់ទោសនេះជាការត្រឹមត្រូវណាស់ ល្អដឹងពីទោស ដឹងពីកំហុសដែលខ្លួនបានធ្វើ ។

ដានី : បាទៗ!អញ្ចឹងពូ ខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំពូទៀតហើយ អញ្ចឹងពូមានចង់បន្ថែម អីពូមានសំនួរអីចុងក្រោយ ពូមានអីចង់បន្ថែម ចង់សំណូមពរអី?

ខន : អត់មានចង់សំណូមពរអីទេ ។

ដានី : បាទ!អញ្ចឹងខ្ញុំអរគុណពូច្រើនដែលចំណាយពេលជួប ផ្តល់សម្ភាសន៍ជាមួយពួកខ្ញុំទាក់ទងពីជីវិតរបស់ពូ ។

ខន : បាទៗ!

ដានី : បាទ!ខ្ញុំអរគុណពូច្រើន ។

ខន : បាទៗ!

**ចប់**